# ខេត្តសៀមរាប–អង្គរក្នុងអំឡុងសង្គ្រាម (១៩៧០–១៩៧៥) និងសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥–១៩៧៩)៖ ពីអំពើហិង្សាមកលទ្ធិផ្ដាច់ការ*

ដោយ ហង់រី ឡូការដ៍

## មូលន័យសង្ខេប

*អត្ថបទនេះទាក់ទងជាពិសេសទៅលើតំបន់បុរាណដ្ឋានអង្គរនិងទីក្រុងសៀមរាប ក្នុងអំឡុងឆ្នាំដែលមានសង្គ្រាមស៊ីវិល (១៩៧០–១៩៧៥) និងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥–១៩៧៩) ដែលយកមធ្យោបាយដឹកនាំដោយប្រើគំរូផ្ទាល់ខ្លួន ។ ការងារអភិរក្សរបស់ក្រុមបារាំងអាចបន្តទៅបានជាមួយនឹងការកែទម្រង់មួយចំនួននៅឯអង្គរក្នុងអំឡុងដើមទសវត្សរ៍ឆ្នាំ ១៩៧០ ។ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អ្នកស្រុកនៅក្នុងតំបន់នោះត្រូវគេជម្លៀសចេញឲ្យទៅកាន់ភាគខាងជើង ដើម្បីបើកច្រកសម្រាប់ការទស្សនារបស់គណៈប្រតិភូបរទេស ជាពិសេសពួកចិន ។ ពួកធ្វើបដិវត្តន៍ក៏បានចូលមកដល់ទីរួមខេត្តសៀមរាបនៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ផងដែរ ។ ពួកគេមិនបានធ្វើការជម្លៀសប្រជាជនចេញភ្លាមៗ ដូចនៅភ្នំពេញនោះទេ ព្រោះជាប់ដៃក្នុងការប្រារព្ធពិធីអបអរជ័យជម្នះនៅក្នុងមីទិញ (ការជួបជុំ) ដ៏ធំមួយ ដែលមានព្រះសង្ឃបីបួនក្រុម ក្នុងមួយក្រុមៗ មានប្រមាណជា ២០ អង្គ ចូលរួមផងដែរ នៅក្នុងបរិវេណថែវទីមួយនៃប្រាសាទអង្គរវត្ត ។ ប្រាសាទជាច្រើននៅក្នុងតំបន់បុរាណដ្ឋាន ត្រូវបានគេបោះបង់ចោលនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ តែក៏មានកន្លែងខ្លះត្រូវបានគេបោសសម្អាតក្នុងឆ្នាំ ១៩៧៨ នៅពេលដែលពួកខ្មែរក្រហមមានផែនការបើកតំបន់នោះឡើងវិញ ដើម្បីទទួលភ្ញៀវទេសចរបរទេសមួយចំនួន ។ ពួកគេមិនបានបំផ្លាញវត្តអារាមណាមួយទេ ប៉ុន្តែប្រើវត្តទាំងនោះធ្វើជាមូលដ្ឋានទ័ព ហើយចាប់ព្រះសង្ឃផ្សឹក ។ សមាជិកនៃនាយកដ្ឋានអភិរក្សស្ទើរតែទាំងអស់ រួមទាំងក្រុមគ្រួសាររបស់ពួកគេ បានរួចរស់ជីវិត ។ ពួកគេត្រូវបានជម្លៀសឲ្យទៅនៅឯភូមិប្រមូលផ្ដុំតូចៗ នៅឯតំបន់ល្វេស–បាគង ព្រោះអង្គការច្បាស់ជាមានផែនការប្រើប្រាស់ពួកគេនៅក្នុងដំណាក់កាលណាមួយនៅពេលខាងមុខមិនខាន ។ ខេត្តសៀមរាបមានគុកចំណាស់មួយបន្សល់តាំងពីសម័យអាណានិគម ត្រូវបានគេប្រើប្រាស់សម្រាប់ឃុំអ្នកទោសដែលពួកគេទាំងនោះមានវាសនាមិនខុសពីអ្នកដែលជាប់ឃុំនៅ ស–២១ និងជើងឯកឡើយ ។ សម្រាប់ពួកខ្មែរក្រហម អង្គរ គឺជានិមិត្តសញ្ញានៃការស្អប់ខ្ពើមពួកសក្តិភូមិផង និងក៏ជាមោទនភាពដ៏អស្ចារ្យផងដែរ ព្រោះវាបានបង្ហាញថា ខ្មែរមានលទ្ធភាពក្នុងការសម្រេចការងារគ្រប់យ៉ាងបាន ។ ព័ត៌មានលម្អិតក្នុងអត្ថបទនេះ ត្រូវបានប្រមូលតាមរយៈការធ្វើបទសម្ភាសន៍ជាមួយប្រជាជនក្នុងតំបន់នៅចន្លោះពីឆ្នាំ ១៩៩១ ដល់ ២០០៤ ។*

---

* ខ្ញុំសូមថ្លែងអំណរគុណដល់លោក ធុន ធារ៉ា ដែលបានបកប្រែអត្ថបទនេះពីភាសាអង់គ្លេស ។

## ក. ការឈានដល់អំពើហិង្សាក្នុងឆ្នាំនៃសង្គ្រាម ១៩៧០–១៩៧៥

### ១– មូលហេតុនៃសង្គ្រាម

*ការដេះឥទ្ធិពលយ៉ាងរហ័សនៃការបាត់បង់អំណាចរបស់ព្រះប្រមុខរដ្ឋសម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០ បានបន្ថយភាពតានតឹងដល់កងទ័ពវៀតណាម ដែលស្ថិតនៅតាមព្រំដែនក្នុងទឹកដីរបស់ខ្លួន និងបានទាញប្រទេសកម្ពុជាឲ្យធ្លាក់ទៅក្នុងសង្គ្រាមឥណ្ឌូចិនទាំងស្រុង*[១] *។ កងទ័ពវៀតណាមបានមកដល់អង្គរក្នុងរយៈពេលពីពីរទៅបីសប្តាហ៍បន្ទាប់ ដោយពួកគេទាំងអស់បានពាក់សញ្ញារូបព្រះឆាយាលក្ខណ៍របស់សម្តេចព្រះសីហនុ ហើយទាហានរបស់ក្រុមសាធារណរដ្ឋមិនដែលបានគ្រប់គ្រងតំបន់ដ៏គួរឲ្យកត់សម្គាល់នេះវិញឡើយ ។ ទីតាំងសមរភូមិមុខពេញមួយសម័យកាលនោះគឺស្ថិតនៅប្រមាណមួយគីឡូម៉ែត្រប៉ែកខាងជើងនៃសណ្ឋាគារហ្រ្គង់អូតែលអង្គរ ហើយក៏ស្ថិតនៅជៀងខាងជើងនៃកន្លែងដែលគេធ្លាប់យកធ្វើជាវិទ្យាល័យជយវរ្ម័ន ទី ២*[២] *នៅសៀមរាប និងដែលសព្វថ្ងៃនេះ បានប្តូរទៅជាសាលាគរុកោសល្យខេត្ត ។ ដូចនេះ ទីក្រុងនេះ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់របបនៅភ្នំពេញ រីឯតំបន់បុរាណដ្ឋានវិញ គឺស្ថិតក្រោមការគ្រប់គ្រងរបស់ពួកបដិវត្ត ។*

*ទីតាំងនោះ គឺជាមូលដ្ឋានយោធា ដែលស្ថិតនៅក្នុងបុព្វហេតុនៃវិនាសកម្មក្នុងអំឡុងពេលប្រយុទ្ធគ្នាប្រាំឆ្នាំនោះ ។ នៅពាសពេញផ្ទៃប្រទេស ពួកបដិវត្តអាចកាន់កាប់បានយ៉ាងឆាប់រហ័ស នូវទីជនបទដែលមានប្រជាជនរស់នៅតិចតួច និងតំបន់ដាច់ស្រយាលឆ្ងាយៗ តែពួកគេមិនមានលទ្ធភាពក្នុងការគ្រប់គ្រងទៅលើទីរួមខេត្តទាំងនោះបានភ្លាមនោះទេ លើកលែងតែបណ្តាទីរួមខេត្តនៅភាគឦសានចេញ ។ ទន្ទឹមនឹងនេះ សៀវភៅកំណត់ហេតុ ដែលមិនទាន់បោះពុម្ពផ្សាយរបស់លោកឧត្តមសេនីយ៍ សូស្ទែន ហ្វែរណង់ដែស ដែលជាមេទ័ពរបស់ពួកសាធារណរដ្ឋ បានឲ្យដឹងថា កងកម្លាំងរបស់ក្រុងភ្នំពេញ បាននិងកំពុងប្រយុទ្ធនៅក្នុងសង្គ្រាមបែបបុរាណមួយ ដែលវាជាការឈ្លានពាននៅក្នុងដំណាក់កាលបីឆ្នាំដំបូង ។ ពួកវៀតណាមបានធ្វើការហ្វឹកហ្វឺនយុវជននៅតាមភូមិ ឲ្យចូលបម្រើបដិវត្តន៍ នៅបន្ទាប់ពីពួកគេបានសម្លាប់មេដឹកនាំក្នុងតំបន់ទាំងនោះ ដូចជា មេភូមិឬមេឃុំក្នុងតំបន់ដែលវាយបាន ហើយពួកខ្មែរក្រហមដែលជាជនបដិវត្តដំបូងៗ នោះ បានត្រាប់តាមនូវសកម្មភាពនេះ ។ នៅបន្ទាប់ពីកិច្ចព្រមព្រៀងប៉ារីស ខែមករា ឆ្នាំ ១៩៧៣ ដែលជាការបើកផ្លូវនៃការដកទ័ពអាមេរិកចេញពីឥណ្ឌូចិន ហើយដែលជំរុញឲ្យទាហានខ្មែរ (ខាងសាធារណរដ្ឋ) ក្រោមការដឹកនាំរបស់លោក ហ្វែរណង់ដែស ប្រែទៅជាប្រឈមមុខក្នុងការប្រយុទ្ធបន្លូរឈាមជាមួយនឹងជនរួមជាតិឯង (ពួកខ្មែរក្រហម) ។ នៅខណៈដែលសង្គ្រាមនៅប្រទេសវៀតណាមខាងត្បូង បានក្លាយទៅជាការប្រយុទ្ធវៀតណាមទល់នឹងវៀតណាម (នៅបន្ទាប់ពីការដកចេញរបស់អាមេរិក) ហើយទាហានរបស់វៀតណាម (នៅកម្ពុជា) ស្ទើរតែទាំងអស់ បានត្រឡប់ទៅផ្ទះវិញ ជម្លោះនៅកម្ពុជាបានក្លាយទៅជាសង្គ្រាមស៊ីវិលដ៏ជូរចត់មួយ ។ ជម្លោះប្រដាប់អាវុធបានកើតមានជាប្រចាំ នៅតាមសមរភូមិជួរមុខ*

---

**(១)** សូមមើល ដេវីឌ ឆាណ្ឌលឺរ, *The Tragedy of Cambodian History* [**សោកនាដកម្មនៃប្រវត្តិសាស្រ្តប្រទេសកម្ពុជា**] យ៉េល គ្រឹះស្ថានបោះពុម្ពផ្សាយសាកលវិទ្យាល័យយ៉េល គ.ស. ១៩៩១ ទ. ២០១ ។

**(២)** រជ្ជកាលពីឆ្នាំប្រហែល គ.ស. ៧៧០ រហូតដល់បន្ទាប់ពី គ.ស. ៨៣០ និងការលើករាជធានីខ្មែរទៅតាំងនៅតំបន់អង្គរក្នុង គ.ស. ៨០២ ។ គេក៏ដឹងផងដែរថា ព្រះអង្គបានបង្កើតពិធីបូជាចំពោះទេវរាជ ។

ហើយវាបានបន្តឲ្យមានទាហានស្លាប់ទាំងសងខាង ដែលសាកសពទាហានទាំងនោះមានក្លិនស្អុយមិនអាចទ្រាំបាន [៣] រហូតដល់ជ័យជម្នះចុងក្រោយនៅថ្ងៃទី ១៧ ខែមេសា ១៩៧៥ ។

## ២– ការប្រណាំងប្រជែងបញ្ចូលយុវជនទៅក្នុងក្រុមទាំងសងខាង

ពេលនោះ គឺជាឆ្នាំដែលយុវជន ដោយរាប់ទាំងអ្នកក្នុងវ័យជំទើរ ។ ត្រូវបានគេចាប់បង្ខំឲ្យចូលធ្វើទ័ព ទាំងខាងក្រុមរបស់ លន់ នល់ ទាំងខាងអង្គការដ៏អាថ៌កំបាំងផងដែរ ។ ឧទាហរណ៍ ភាគច្រើន (មានប្រមាណជា ៦០%) នៃកម្មករចំនួន ១០០០ នាក់ ដែលបានធ្វើការពង្រីកព្រលានយន្តហោះសៀមរាប កាលពីចុងទសវត្សរ៍ឆ្នាំ ១៩៦០ ក្រោមការជំនួយរបស់ចិន បានចូលរួមជាមួយនឹងបដិវត្តន៍ ។ ពួកគេទាំងនោះ គឺជាគោលដៅដ៏ចម្បងក្នុងការជួយពង្រីកការឃោសនាលទ្ធិបែបម៉ៅនិយមរហូតដល់ឆ្នាំ ១៩៦៩ ។ ជាក់ស្តែង ឈ្មោះ ស្វាយ សារឿន [៤] ដែលជាកម្មករមួយនាក់នៅឯព្រលានយន្តហោះកាលពីឆ្នាំ ១៩៦៩ បានទទួលមេដាយរូបម៉ៅចំនួនបួន ។ ពួកកម្មករត្រូវបានគេបង្រៀននូវចម្រៀងបដិវត្តរបស់ចិន ដូចជា បទ «ព្រះអាទិត្យរះនៅទិសខាងកើត» ហើយថែមទាំងបង្រៀនទៀតថា អ្វីៗ ទាំងអស់ដែលអាចមានលើលោកយើងនេះ គឺជាស្នាដៃរបស់ប្រមុខ ម៉ៅ ។ សមមិត្ត ម៉ៅ បានផ្តល់ឲ្យមនុស្សនៅលើលោកយើងនេះ នូវអ្វីៗ សព្វបែបយ៉ាង ។

ពួកកម្មករត្រូវមើលខ្សែភាពយន្តឯកសាររបស់ម៉ៅ ។ មានរឿងមួយនោះបានបង្ហាញនូវរូងដ៏ធំមួយ ដែលគេកំពុងជីក មានជម្រៅប្រមាណជា ១០ ទៅ ២០ ម៉ែត្រ ។ នៅពាក់កណ្តាលផ្លូវនៃរណ្តៅនោះចុះទៅក្រោម គេបានជីកផ្លូវរូងផ្តេកដែលអាចឲ្យក្មេងៗ យុវជនជំទង់ និងមនុស្សចាស់ជរា អាចចូលទៅខាងក្នុង ដើម្បីការពារខ្លួនពីការទម្លាក់គ្រាប់បែករបស់ពួកអាមេរិកាំងនិងបារាំងនេះ បើតាមការអះអាងរបស់ពួកគេក្នុងខ្សែភាពយន្ត ។ គេបានជីករណ្តៅដទៃទៀត ដើម្បីឲ្យមានខ្យល់ចេញចូល ។ ពួកចក្រពត្តិនិយមបានទម្លាក់គ្រាប់បែកទៅលើរណ្តៅធំៗ ទាំងនោះ ហើយពួកគេជឿជាក់ថាមនុស្សគ្រប់គ្នាក្នុងនោះច្បាស់ជាស្លាប់មិនខាន ។ តែតាមពិត មិនមាននរណាម្នាក់បានស្លាប់នោះទេ ។ នៅក្នុងការពិតជាក់ស្តែង មានរណ្តៅជាច្រើន ដែលគេបានជីកជាមួយនឹងផ្លូវខាងក្រោមតូចៗ ដែលសំដៅទៅទីកណ្តាលមួយ ។ វាជាទីតាំងសម្រាប់លាក់បំពួនពីពួកចក្រពត្តិ ក៏ដូចជាអាណានិគមនិយម ។ មានបន្ទប់ក្រោមដីតូចៗ ជាច្រើន ដែលគ្រួសារទាំងអស់អាចគៀសខ្លួនទៅពួនបាន ។ នៅពេលដែលមានការគំរាមទម្លាក់គ្រាប់បែក អ្នកយកការណ៍របស់ចិនបានធ្វើដំណើរពីភូមិមួយទៅភូមិមួយដោយការធាក់កង់ ដើម្បីប្រាប់ជាដំណឹងដល់ប្រជាជន ។ តែយ៉ាងណាក៏ដោយ លោក ស្វាយ សារឿន មិនបានជឿទៅលើការឃោសនាទាំងនោះទេ ដោយសារតែឪពុករបស់គាត់ គឺជាប៉ូលិសមួយរូប ។ នៅពេលនោះ អ្នកជំនាញការចិន បានប្រគល់ឲ្យកម្មករគ្រប់រូបនូវឯកសណ្ឋានយោធាព័ណ៌កាគីស្បែកជើង និងកាដុងទឹកមួយ ។ ទន្ទឹមនឹងនេះ មានលោកនេនជាច្រើនអង្គនៅតាមវត្តក្នុងខេត្តសៀមរាប បានសឹក និងសម្រេចជ្រើសរើសចូលបម្រើក្នុងភាគីមួយ ក្នុងចំណោមភាគីទាំងពីរ ។

---

**(៣)** ដោយផ្អែកទៅតាមការអះអាងរបស់លោក អែម សារឿន កើតឆ្នាំ ១៩៥៧, សម្ភាសនៅថ្ងៃទី ១១ មករា ២០០១ នៅក្នុងស្រុកបន្ទាយស្រី ។

**(៤)** កើតឆ្នាំ ១៩៥០, សម្ភាសកាលពីថ្ងៃទី ១៨ កក្កដា ១៩៩១ ។

*ឧទាហរណ៍ នៅឯវត្តកេសរារាម ដែលជាវត្តធម្មយុត្តិកនិកាយ ធ្លាប់តែមានព្រះសង្ឃប្រមាណជា ៥០ អង្គ ប្រែជាមាននៅសល់តែព្រះសង្ឃវ័យចំណាស់ៗ តែបីអង្គប៉ុណ្ណោះ នៅបន្ទាប់ពីគេវាយបានទីរួមខេត្តមក ។ ព្រះសង្ឃនិងលោកនេនអាចទៅចូលរួមជាមួយនឹងពួកបដិវត្ត ឬក៏ខាងសាធារណរដ្ឋ ។*

### ៣– ការងារអភិរក្សក្នុងសម័យសង្គ្រាម

*នៅតំបន់ការងារអភិរក្សនៃប្រាសាទបាពួន លោក ប៊ែរណារដ៍-ហ៊ីលីព្ព ហ្គ្រោស្លីយេ៉រ៍ បានរុះថ្មប្រាសាទចេញ ដើម្បីកសាងជាគ្រឹះថ្មី ដែលមានភាពរឹងមាំជាងមុន ហើយពួកវៀតណាមបានអនុញ្ញាតឲ្យក្រុមរបស់គាត់ បន្តការងារដ៏លំបាកនេះ ។ យើងទាំងអស់គ្នាគួរតែថ្លែងអំណរគុណចំពោះនយោបាយការទូតរបស់ជនបារាំងរូបនេះ ។ ការងារនេះបានបន្តចាប់តាំងពីខែមិថុនា ឆ្នាំ ១៩៧០ ហើយលោក ហ្គ្រោស្លីយេ៉រ៍ អាចបន្តជិះកង់ទៅមកក្នុងទីរួមខេត្តសៀមរាបបានពេញមួយឆ្នាំ ១៩៧១ ។ ប៉ុន្តែ អ្វីគ្រប់យ៉ាងត្រូវបានបញ្ចប់ជារៀងរហូត ចាប់តាំងពីថ្ងៃទី ២០ ខែកមរា ឆ្នាំ១៩៧២ មក ។ ពួកបដិវត្តបានរឹបអូសគ្រឿងចក្រធុនធ្ងន់នានា ហើយក៏បានបង្ខំកម្មករមួយចំនួនឲ្យចូលបម្រើក្នុងជួរបដិវត្តទៀតផង ។ ពួកគេមិនបានអនុញ្ញាតលោក ហ្គ្រោស្លីយេ៉រ៍ ឲ្យចូលទៅមើលខាងក្នុងតំបន់បុរាណដ្ឋាននេះទៀតឡើយ តែគាត់បានទៅបើកការដ្ឋានថ្មីៗ នៅឯប្រាសាទព្រះឥន្ទកោសិយ ដែលស្ថិតនៅក្បែរទីប្រជុំជនសៀមរាប ហើយបន្ទាប់មកទៅជួសជុសនៅឯវត្តអថ្វា ស្ថិតនៅតាមដងស្ទឹង នៅតាមផ្លូវទៅកាន់បឹងទន្លេសាប ។ រូបគាត់មានការព្រួយបារម្ភក្នុងការបន្តការងារឲ្យមានលក្ខណៈប្រក្រតី និងការផ្តល់នូវប្រាក់ចំណូលទៀងទាត់សម្រាប់គ្រួសារជាច្រើន ដែលរស់ដោយសារតែការធ្វើការរបស់ពួកគេនៅឯការដ្ឋានអភិរក្ស*(៥) *។ ប៉ុន្តែ នៅដើមខែមករា ឆ្នាំ ១៩៧៤ បន្ទាប់ពីទទួលរងរបួសដោយសារចោរប្លន់នៅក្រុងភ្នំពេញមក លោក ហ្គ្រោស្លីយេ៉រ៍ បានចាកចេញពីប្រទេសកម្ពុជាជារៀងរហូត ។ គាត់បានផ្ទេរការងារទៅឲ្យអនុប្រធានវ័យក្មេងរបស់គាត់ ឈ្មោះ ពេជ កែវ ជំនួសវិញ ។ លិខិតជាផ្លូវការមួយមកពីរដ្ឋមន្ត្រីក្រសួងវប្បធម៌ បានតែងតាំងគាត់ធ្វើជាអ្នកស្នងរបស់លោក ហ្គ្រោស្លីយេ៉រ៍ និងបានប្រគល់ឲ្យគាត់នូវកូនសោទាំងអស់នៃការដ្ឋានអភិរក្សក្នុងខេត្តសៀមរាប ។*

## ខ. ថ្ងៃ ១៧ មេសា ១៩៧៥ នៅខេត្តសៀមរាប

*អ្វីដែលបានកើតឡើងពេលក្រុមឧទ្ទាម (ពួកខ្មែរក្រហម) មកដល់ទីរួមខេត្តសៀមរាបនោះ គឺមានលក្ខណៈដូចគ្នាច្រើនទៅនឹងទីរួមខេត្តផ្សេងៗ ទៀត តែក៏មានភាពដោយឡែកសំខាន់ៗ មួយចំនួនផងដែរ ។ ដំបូងបង្អស់ ពួកខ្មែរក្រហមត្រូវតែខំខ្នះខ្នែងដណ្តើមយកទីក្រុង ដែលជារាជធានីចាស់ នៅក្នុងថ្ងៃតែមួយ ដូចនៅក្រុងភ្នំពេញ ដែលជាក្រុងសម័យថ្មីដែរ ។ ពួកគេមានការបារម្ភជាបឋម គឺការដកអាវុធពីប្រជាជន និងចាប់ប្រមូលអ្នកដឹកនាំពីសម័យមុន ហើយបានទុករយៈពេលឲ្យប្រជាជនបីបួនថ្ងៃមុនពេលចាប់ផ្តើមធ្វើការជម្លៀសចេញ (ពីទីប្រជុំជនសៀមរាប) ។ នៅខណៈដែលថ្នាក់ដឹកនាំខ្មែរក្រហមបានកសាងឡើងនូវនយោបាយឧក្រិដ្ឋ ពួកគេក៏បានបញ្ចូលគំនិតដ៏ច្របូកច្របល់មួយចំនួន ដែល*

---

**(៥)** សម្ភាសន៍ជាមួយនឹងលោក ពេជ កែវ ដែលកើតនៅឆ្នាំ ១៩៤៤, កាលពីថ្ងៃទី ១៣ មិថុនា ២០០៤ ។

ពួកគេបានបង្កើតឡើង ។ ដូចដែលបានឃើញផ្ទាល់ដោយភ្នែករបស់សាក្សី ក៏ដូចជាមនុស្សពិសេសបីនាក់ថែមទៀត (គឺបុរាណវិទូ ពេជ កែវ ម្នាក់ និងព្រះសង្ឃពីរអង្គទៀត គឺ ព្រះតេជគុណ ពុធ ប៉ុណ្ណ និងព្រះតេជគុណ ទេព វង្ស) ដែលបានថ្លែងថា ថ្ងៃកំណាច និងរឿងរ៉ាវដែលបានកើតនៅពេលបន្តបន្ទាប់កាលនោះ គឺត្រូវបានកត់សម្គាល់ដោយព្រឹត្តិការណ៍ចំនួនបីសំខាន់ៗ ហើយមានលក្ខណៈខុសពីការបណ្តេញប្រជាជនទាំងអស់ចេញ ដូចដែលបានធ្វើនៅទីកន្លែងផ្សេងទៀតនៅទូទាំងប្រទេស ។

## ១– ការសម្លាប់រង្គាលពួកវរជន

ពួកវរជនក្នុងសម័យសង្គមចាស់ និងសម័យសាធារណរដ្ឋ មន្ត្រីស៊ីវិល និងនាយទាហាន ត្រូវគេចាប់ដាក់ទៅក្នុងឡានទ្រុង ហើយដឹកបញ្ជូនទៅកាន់វត្តសម័យទំនើបមួយ ស្ថិតនៅក្បែរប្រាសាទលលៃនៅក្នុងតំបន់រលួស ប៉ែកខាងកើតនៃទីរួមខេត្តសៀមរាប ។ វត្តនោះ ត្រូវប្រើជាកន្លែងឃុំឃាំងអ្នកទោសនៅខណៈដែលពួកអ្នកទោសទាំងនោះត្រូវគេចងដាប់ ហើយឲ្យគេឆែកអត្តសញ្ញាណពួកគេ ។ ពួកគេត្រូវគេសួរចម្លើយនៅទីដែលមានចម្ងាយប្រមាណជា ៥០០ ម៉ែត្រឯខាងជើងវត្ត ។ បន្ទាប់មក ពួកគេត្រូវបានគេនាំឲ្យប្រមាណជាមួយគីឡូម៉ែត្របន្ថែមទៀត ទៅកាន់ទិសឦសាន ដើម្បីធ្វើការកម្ទេចចោល ។ ទីកន្លែងរណ្តៅកប់សាកសពរួមទាំងនោះ មានបណ្តោយវែងៗ ហើយដែលមនុស្សម្នាក់ក្នុងចំណោមអ្នកជីករណ្តៅនោះ មកពីក្រុមអ្នកអភិរក្ស ។ វាពិតជាមាននូវជនរងគ្រោះរាប់រយនាក់មិនខាន ប៉ុន្តែក៏អាចមានច្រើនដល់រាប់ពាន់នាក់ផង ក៏មិនដឹង(៦) ។ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ មានឆ្អឹងសាកសពមួយចំនួនតូចប៉ុណ្ណោះ ដែលសល់នៅបរិវេណនោះ ព្រោះគេមិនដែលជីកគាស់រណ្តៅទាំងនោះមើលម្តងណាឡើយ ។ លើកលែងតែក្នុង ឆ្នាំ ១៩៧៩ ប្រជាជនបាននាំគ្នាទៅជីកកាយរកមាសតែប៉ុណ្ណោះ ។ នៅមានសល់តែឆ្អឹងនិងលលាដ៍ក្បាលមួយចំនួនប៉ុណ្ណោះ ដែលត្រូវបានគេយកមកសម្រាប់ប្រារព្ធពិធីថ្ងៃ ២០ ឧសភា ដែលជាទិវាចងកំហឹង ។ នៅខាងក្នុងបរិវេណនៃប្រាសាទដែលសាងនៅដើមសម័យអង្គរដ៏មានកិត្តិនាម គឺប្រាសាទលលៃ មានបន្សល់ទុកនូវរឿងរ៉ាវតូចមួយរបស់ប្រជាជននៃរបបសាធារណរដ្ឋខ្មែរ ដែលពួកគេបានចាត់ទុកថា ជាទីកន្លែងដ៏សំខាន់មួយនៃទិវាចងកំហឹង ២០ ឧសភា ។ គេបានជ្រើសយកកាលបរិច្ឆេទនេះ ព្រោះកាលពីថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៧៦ គឺជាថ្ងៃដែលពួកកម្ពុជាប្រជាធិបតេយ្យហៀបនឹងបង្កើតឲ្យមានជាសមូហភាពនៅទូទាំងប្រទេស ។ តែតាមពិតនៅតាមតំបន់ខ្លះ ដែលត្រូវបានគ្រប់គ្រងដោយពួកបដិវត្តរួចទៅហើយនោះ សហករណ៍ត្រូវបានដាក់បញ្ចូលឲ្យមានជាផ្លូវការក្នុងពេលបីឆ្នាំមុន គឺតាំងពីថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៧៣ មកម្ល៉េះ ។

## ២– ជោគវាសនាព្រះសង្ឃ និងពិធីបុណ្យនៅអង្គរវត្ត

ព្រះសង្ឃព្រះពុទ្ធសាសនា ហាក់ដូចជាមិនត្រូវបានកត់សម្គាល់ចូលទៅក្នុងចំណោមនៃក្រុមពួកវរជនទេ នៅក្នុងកិច្ចប្រតិបត្តិការភ្លាមៗ នៅគ្រាដំបូងនៅតំបន់លលៃ ។ តែវាមានលក្ខណៈផ្ទុយទៅ

---

(៦) យោងទៅលើសក្ខីភាពរបស់យាយម៉ៃ កើតឆ្នាំ ១៩៥០, សម្លាសនៅថ្ងៃទី ១០ មករា ២០០១, និងប្តីរបស់គាត់ កុយ ថែម កើតឆ្នាំ ១៩៤៧, សម្លាសនៅថ្ងៃទី ២៤ មករា ១៩៩៤ ។

វិញ បើយោងទៅលើព្រះតេជគុណ ពុធ ប៉ុណ្ណ ដែលជាចៅអធិការវត្តកេសរារាម (អតីតវត្តធម្មយុត្ត) មុនឆ្នាំ ១៩៧៥[៧] ។ រូបលោកបានបួសជាសាមណេរ ក្នុងព្រះជន្ម ១២ វស្សានៅឯវត្តនួនមណីរាម ហៅ វត្តថាន់ នៅក្រុងភ្នំពេញ ហើយបានបួសជាភិក្ខុនៅព្រះជន្ម ១៦ វស្សា ។ រូបលោកត្រូវបាន បញ្ជូនទៅសៀមរាបក្នុងឆ្នាំ ១៩៧៤ ។ លោកបាននិមន្តទៅជាមួយនឹងព្រះសង្ឃពីរអង្គផ្សេងទៀត ។ នៅពេលដែលទីរួមខេត្តសៀមរាបធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហមទាំងស្រុង សាមណេរ ទាំងអស់ត្រូវចាកចេញ ហើយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ។ នៅពេលដែលពួកខ្មែរ ក្រហមចូលក្នុងទីរួមខេត្តសៀមរាប នៅថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥ ពួកគេក៏បានទៅកាន់ទីវត្ត អារាម ហើយរូបលោក (ពុធ ប៉ុណ្ណ) ត្រូវបានគេសួរថា តើតេជគុណមកពីណា? លោកបានឆ្លើយតប ថា មកពីវត្តថាន់នៅឯក្រុងភ្នំពេញ ។ មានមេដឹកនាំខ្មែរក្រហមម្នាក់ ដែលមកពីច្បារអំពៅ ស្ថិតនៅ ខាងត្បូងភ្នំពេញ ហើយស្ថិតនៅមិនឆ្ងាយពីវត្តថាន់នោះទេ ។ ពួកខ្មែរក្រហមបានបង្កើតគណៈ កម្មាធិការបដិវត្តមួយនៅឯវត្តដំណាក់ ។ នៅថ្ងៃបន្ទាប់ លោកនិងព្រះសង្ឃពីរអង្គទៀត ត្រូវបានគេ ចាប់បញ្ជូនដោយរ៉ឺម៉ក ទៅកាន់បរិវេណនៃក្លោងទ្វារទីមួយនៃប្រាសាទអង្គរវត្ត ដើម្បីចូលរួមក្នុងពិធី អបអរដ៏ធំមួយ លើកសរសើរជោគជ័យ ។ មានមនុស្សជាច្រើនមានវត្តមាន និងមានវេទិកាមួយសង់ ឡើងនៅពីមុខប្រាង្គប្រាសាទអង្គរវត្ត សម្រាប់ពួកមន្ត្រី ហើយក្នុងចំណោមព្រះសង្ឃទាំងនោះ មាន តែមួយអង្គប៉ុណ្ណោះដែលលោកមិនធ្លាប់បានស្គាល់ ។ គេបានដាក់ព្រះតេជគុណ ពុធ ប៉ុណ្ណ ឲ្យគង់ ជាមួយនឹងព្រះសង្ឃប្រមាណជា ៥០ ទៅ ៦០ អង្គ ។ គេបានប្រកាសឲ្យដឹងពីជោគជ័យ ដោយ សំឡេងភ្លេងយ៉ាងរំពង ដែលជាប្រភេទតន្ត្រីប្រពៃណីធ្លាប់តែព្រៀនៅតាមវត្តអារាម ។ សុន្ទរកថាបាន ប្រារព្ធនូវជោគជ័យដ៏ធំធេងបំផុតក្នុងរយៈពេលរាប់ពាន់ឆ្នាំ ។ គេនាំគ្នាសូត្រពាក្យស្លោក ច្រៀង ចម្រៀងបដិវត្ត ហើយសម្តែងរឿងខ្លីៗ ដែលរៀបរាប់ពីបដិវត្តន៍ដ៏អង់អាចផងដែរ ។

ពួកខ្មែរក្រហមបានតម្រូវព្រះសង្ឃឲ្យសូត្រធម៌ **ជយន្តោ** ដែលជាការឧទ្ទិសកុសលបែបប្រពៃណី ឲ្យដល់ពិធីបុណ្យនៃជោគជ័យនេះ ។ ព្រះសង្ឃក៏បានសូត្រធម៌ ដើម្បីអភិសេកពុទ្ធបដិមាមួយអង្គផង ដែរ ។ ដូចនេះហើយបានជាគណៈបក្សកុម្មុយនិស្តកម្ពុជា និងមន្ត្រីតំណាងរបស់ពួកគេនៅតាមតំបន់ កំពុងប្រារព្ធពិធីនៃការទើបតែលេចឡើងនូវយុគសម័យថ្មីមួយ ដែលមានតួនាទីស្ទើរតែដូចជាព្រះថ្មី មួយ ហើយដែលជាអង្គភាពដ៏អាថ៌កំបាំង អរូបិយ និងជាអង្គការបដិវត្ត ។ ពីពេលនេះតទៅ អង្គការ នឹងដើរតួជាអ្នកគ្រប់គ្រងពិភពលោក ។ ខ្ញុំនិយាយថា ពិភពលោក ព្រោះអ្នកដឹកនាំខ្មែរក្រហម ជា ពិសេសអ្នកនៅចំពោះមុខអង្គរវត្ត ពួកគេត្រូវបានធ្វើឲ្យជឿជាក់ទៅលើបដិវត្តន៍កម្ពុជា ដែលមិនត្រឹមតែ នឹងគ្រប់គ្រងកម្ពុជាក្នុងរយៈពេល ១០ ០០០ ឆ្នាំ ដូចដែល នួន ជា បានអះអាងប៉ុណ្ណោះទេ តែអង្គការនេះ នឹងដើរតួនាទីជាគ្រឿងបំភ្លឺផ្លូវដល់ជនលិចលង់ទាំងឡាយ ដែលជាជនរងគ្រោះនៃគ្រោងការដ៏អាក្រក់នៃ ពួកអាណានិគមនិយម ចក្រពត្តិនិយម និងមូលធននិយមក្នុងគ្រប់រូបភាព ។ ទាំងនេះជាអ្វីដែលពិធីបុណ្យ នេះបានប្រកាសឲ្យយើងដឹង ក្រៅពីនេះ នៅមានអ្វីផ្សេងទៀតដែលសម្ងាត់ មិនអាចរាយការណ៍ឲ្យគេ

---

**(៧)** កើតឆ្នាំ ១៩២៣, សម្ភាសនៅសៀមរាប នៅថ្ងៃទី ៦ កក្កដា ១៩៩៤ ។

ដឹង ។ ក៏មានផងដែរនូវសុន្ទរកថារបស់តំណាងក្រុមនីមួយៗ នៃ «ព្រះសង្ឃប្រជាធិបតេយ្យ» ។ ពិធីបុណ្យនោះបានបញ្ចប់នៅម៉ោងប្រមាណជា ១០ យប់ ។

នៅបន្ទាប់ពីក្រុមព្រះអង្គយាងត្រឡប់មកវត្តកេសរារាមវិញ ពួកខ្មែរក្រហមមិនទាន់បានជម្លៀសប្រជាជនចេញពីក្រុងនៅឡើយទេ ។ តែសកម្មភាពនេះបានកើតឡើងនៅថ្ងៃបន្ទាប់ ។ ដោយសារតែវត្តរបស់ព្រះតេជគុណ ពុធ ប៉ុណ្ណ ស្ថិតនៅភាគខាងលិចនៃទីរួមខេត្ត ព្រះអង្គត្រូវបានគេបញ្ជូនឲ្យទៅតាមផ្លូវជាតិលេខ ៦ ឆ្ពោះទៅទិសខាងលិច ខណៈនៅស្មៀកស្បង់គ្រងចីវរនៅឡើយ រួមជាមួយនឹងព្រះសង្ឃដែលជាមិត្តភក្តិព្រះអង្គពីរអង្គទៀត ។ ព្រះសង្ឃទាំងបីព្រះអង្គបាននិមន្តថ្មើរជើងរហូតទៅដល់ស្រុកក្រឡាញ់ បន្ទាប់មកចុះទៅខាងត្បូងឆ្ពោះទៅវត្តសំពៅលូន ដែលមានចម្ងាយ ៥ គ.ម. ពីផ្លូវឆ្ពោះទៅឃុំសម្បូរ នៅតាមបណ្តោយស្ទឹងស្រែង ។ លោកបានជួបជាមួយនឹងមេដឹកនាំខ្មែរក្រហមម្នាក់ដែលបានស្គាល់លោក ហើយបានការពាររូបលោកពេញមួយសម័យ ក្នុងនាមគេជាមេដឹកនាំសហករណ៍ ។ ប្រជាជននៅស្រុកក្រឡាញ់ ត្រូវបានជម្លៀសទៅកាន់ភាគខាងជើង ។ ប្រជាជនទាំងនោះ ក្រោយមក ត្រូវបានគេបញ្ជាឲ្យលើកផ្លូវឆ្ពោះទៅកាន់ភាគខាងត្បូងនៃដងស្ទឹងសង្កែ ។ ព្រះតេជគុណ ទេព វង្ស [៨] ដែលសព្វថ្ងៃនេះ ជាសម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលធ្លាប់ជាគ្រូសូត្រវត្តរាជបូណ៌ (ហៅ វត្តបូព៌) បានបញ្ជាក់បន្ថែមទៅលើសង្ឃដីការបស់ព្រះតេជគុណ ពុធ ប៉ុណ្ណ ថា ពិធីបុណ្យនៅអង្គរវត្តដែលប្រារព្ធធ្វើនោះ មិនមែនមានរយៈមួយល្ងាចទេ តែវាមានរយៈពេលដល់ទៅបីថ្ងៃ ។

សម្តេចព្រះសង្ឃរាជ ទេព វង្ស ប្រសូតនៅភូមិប្រឡាយ ដែលស្ថិតនៅខាងត្បូងទីរួមខេត្តសៀម-រាបតាមបណ្តោយស្ទឹងសៀមរាប ។ ព្រះអង្គបានបួសជាព្រះសង្ឃក្នុងឆ្នាំ ១៩៥២ ជាពេលដែលមានចលនាទាមទារឯករាជ្យ ។ ព្រះអង្គគង់នៅវិហារបុរាណនៃវត្តបូព៌ ដែលក្នុងសម័យសង្គមរាស្ត្រនិយមមានព្រះសង្ឃប្រមាណជា ៨០ ទៅ ១០០ អង្គ ហើយក្នុងសម័យសាធារណរដ្ឋខ្មែរ មានប្រមាណជា ៦០ ទៅ ៧០ អង្គ ។ មានព្រះសង្ឃចំនួន ៦០ អង្គនៅរសៀលថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ដែលជាពេលពួកខ្មែរក្រហមចូលទៅដល់ទីរួមខេត្តសៀមរាប ។ នៅពេលនោះ វត្តបូព៌ គឺជាវត្តធំជាងគេបង្អស់នៅក្នុងទីរួមខេត្ត ។ ក្នុងរយៈពេលបីថ្ងៃបន្ទាប់មក គេបង្ខំព្រះអង្គឲ្យដើរឆ្ពោះទៅប្រាសាទអង្គរវត្ត ហើយចូលរួមក្នុងពិធីដ៏ធំមួយ ដើម្បីប្រារព្ធនូវជោគជ័យដ៏ត្រចះត្រចង់ ដែលមានមនុស្សចូលរួមមិនតិចជាង ៥០០០ នាក់ឡើយ ។ ក៏មានផងដែរនូវព្រះសង្ឃចំនួនពីរក្រុម ដែលហាក់មិនមានលក្ខណៈដូចគ្នាឡើយ គឺមួយក្រុមមាន ៣០ អង្គដែលនិមន្តមកពីទីរួមខេត្តសៀមរាប និងមួយក្រុមទៀតដែលមានចំនួនច្រើនជាងមានព្រះសង្ឃ ១០០ អង្គ និមន្តមកពីតំបន់រំដោះ ។ មានមនុស្សមួយក្រុមទៀត ដែលមានប្រជាជនសាមញ្ញប្រមាណជា ១០០ នាក់ប៉ុណ្ណោះ ដែលមកពីតំបន់របស់ពួកសាធារណរដ្ឋនៃខេត្តសៀមរាប ។ មានព្រះសង្ឃបដិវត្តគង់នៅក្នុងវត្តស្ថិតនៅទិសខាងត្បូងនៃបរិវេណប្រាសាទអង្គរវត្ត ហើយព្រះសង្ឃទាំងនោះ មិនដែលបានចូលលាយឡំជាមួយនឹងព្រះសង្ឃឯទៀតនៅសៀមរាបម្តងណាឡើយ ។

---

(៨) សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស ប្រសូតក្នុងឆ្នាំ ១៩៣២, សម្ពាសនៅភ្នំពេញ នៅថ្ងៃទី ១ កក្កដា ២០០៤ ។

*មានការថ្លែងសុន្ទរកថា ប្រគំតន្ត្រី សម្តែងល្ខោននិងចម្រៀងបដិវត្ត ។* « ពួកចក្រពត្តិនិយម ពួកមូលធននិយម បានស៊ីសាច់ ជញ្ជក់ឈាម និងធ្វើឲ្យប្រជាជនស៊ីដូចជាសត្វឆ្កែ អស់រយៈពេលលើសពី ២០០០ ឆ្នាំមកហើយ ។ ឥឡូវនេះ ពួកវាបានទទួលបរាជ័យទាំងស្រុង[៩] » *។ គឺ កែ ពក ជាអធិបតីនៃការប្រារព្ធពិធីបុណ្យនៃជោគជ័យដ៏ធំនោះ ។ ដោយផ្តោតទៅលើកំពូលទាំងប្រាំនៃប្រាសាទអង្គរវត្តដែលស្ថិតនៅពីក្រោយ កែ ពក បាននិយាយពេញដោយអំណួតថា ÷* « ជយោ! នេះគឺជាជោគជ័យដ៏ត្រចះត្រចង់របស់ប្រជាជនកម្ពុជា និងមានភាពប្រសើរជាងកំពូលនៃប្រាសាទអង្គរវត្តទៅទៀត[១០] » *។ ការសម្តែងរឿងខ្លីៗ ទាក់ទងនឹងបដិវត្តន៍ក៏មានឡើងក្នុងកាយវិការនៃការធ្វើត្រាប់តាមសកម្មភាពដ៏អង់អាចរបស់នីរសា ក៏ដូចជាយុទ្ធជន ការដាក់អង្គប់បុស្ស៊ី សហករណ៍ថ្មីដែលទើបនឹងបង្កើតឡើង ឬក៏អំពីចលនានៃការដឹកជញ្ជូនសន្ទូងយកទៅស្រែ ។ល។ ព្រះតេជគុណ ទេព វង្ស ត្រូវនិមន្តលើផ្លូវអស់រយៈបីថ្ងៃ ហើយព្រះអង្គក៏បានខ្វប់អង្ករយកទៅជាមួយ ដូចព្រះសង្ឃឯទៀតដែរ ។ នៅបន្ទាប់ពីត្រឡប់មកសៀមរាបវិញ ព្រះអង្គត្រូវបានគេជម្លៀសដោយនិមន្តផ្ទាល់នឹងព្រះបាទ និងនៅស្លៀកស្បង់គ្រងចីវរនៅឡើយ ជាមួយនឹងព្រះសង្ឃឯទៀត ឆ្ពោះទៅភូមិក្បាលដំរី ឃុំពង្រលើ ប្រមាណជា ១៥ ទៅ ១៨ គ.ម. ខាងជើងកំពង់ក្តី ស្រុកជីក្រែង ។ ព្រះអង្គជាសង្ឃដែលត្រូវគេបង្ខំឲ្យផ្សឹក លុះដល់ខែវិច្ឆិកាក្នុងឆ្នាំដដែល (១៩៧៥) ប៉ុណ្ណោះ និងត្រូវបានបង្ខំឲ្យធ្វើការយ៉ាងលំបាកដូចមនុស្សសាមញ្ញឯទៀតដែរ ។ បន្ទាប់មក លោកត្រូវបានបញ្ជូនទៅភូមិកំណើត ឈ្មោះភូមិប្រឡាយ នៅថ្ងៃ ១៤ វិច្ឆិកា ។ ព្រះតេជគុណ ទេព វង្ស មិនបានលើកឡើងអំពីការសម្លាប់រង្គាលព្រះសង្ឃក្នុងពេលធ្វើបទសម្ភាសន៍នោះទេ ក្រៅពីលើកឡើងពីការបង្ខំឲ្យផ្សឹក[១១] ។*

*មិនមានឡើយនូវការលើកឡើងអំពីការប្រារព្ធពិធីអបអរនៅអង្គរវត្តនៅក្នុងកម្រងឯកសារ ដែលបោះពុម្ពស្តីពីអក្សរសិល្ប៍នៃកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមានពិធីបុណ្យមួយផ្សេងទៀតស្រដៀងនេះដែលបានប្រារព្ធឡើងនៅឯពហុកីឡាដ្ឋានអូឡាំពិច ក្នុងរយៈពេលប្រមាណជាពីរសប្តាហ៍បន្ទាប់ពីទទួលបានជោគជ័យ ។ ពួកខ្មែរក្រហមមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំពិធីអបអរនៅថ្ងៃទី ១៧–១៩ មេសា ឆ្នាំ ១៩៧៥ (នៅឯសៀមរាប) ដោយសារតែពួកគេបានគ្រប់គ្រងតំបន់នោះអស់រយៈពេលប្រាំឆ្នាំមកហើយ ។ ទន្ទឹមនឹងនេះ បទភ្លេងជាតិទីមួយរបស់ពួកគេ លើកដាក់ព្រះសង្ឃព្រះពុទ្ធសាសនាក៏ដូចប្រជាជនសាមញ្ញធម្មតាផងដែរ ÷*

« ឈាមក្រហមឆ្អៅ ក្រាលនៅលើប្រឹថពី ឈាមដែលពលី រំដោះអស់ប្រជាជន
ឈាមកម្មករ កសិករ បញ្ញាជន ឈាមយុវជន **ព្រះសង្ឃ** ហើយនិងនារី ឈាមក្ដួចអណ្តែត
ត្រសៃតលើមេឃា ប្រែក្លាយជាទង់ក្រហមបដិវត្ត [បន្ទរ] ទង់ក្រហមអណ្តែតហើយ មិត្ត

---

**(៩)** កំណត់បណ្ណាធិការ ៖ សម្រង់នេះ ត្រូវបានបកប្រែពីភាសាអង់គ្លេស ព្រោះរកអត្ថបទដើមជាខេមរភាសាពុំឃើញ ។

**(១០)** ដដែល ។

**(១១)** សូមមើល *Buddhism under Pol Pot* [ព្រះពុទ្ធសាសនាក្រោមរបប ប៉ុល ពត] ដោយ អៀន ហារីស (Ian Harris), ភ្នំពេញ មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ១៣ គ.ស. ២០០៧ ដែលសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស មានព្រះបន្ទូលពីព្រះសង្ឃចំនួន ៥៧ អង្គ ដែលត្រូវបានគេធ្វើគត់ ។ តែព្រះអង្គមិនបានលើកឡើងពីឃាតកម្មទាំងនោះប្រាប់ខ្ញុំទេ ។

> យើងអើយពុះពារសម្រុកវាយខ្លាំង ទង់ក្រហម ទង់ក្រហម អណ្តែតហើយ អណ្តែតហើយ កំហឹងគ្មានស្បើយបក់បោកដូចព្យុះសង្ឃរា ទង់ក្រហម ទង់ក្រហម អណ្តែតហើយ អណ្តែតហើយ កុំទុកឡើយចក្រពត្តិប្រតិកិរិយា កម្ទេចឲ្យអស់ពីកម្ពុជាពុះពារសម្រុក សម្រុកយកជ័យជម្នះ! ជ័យជម្នះ! ជ័យជម្នះ! » ។

*ជាការច្បាស់ណាស់ថា ពួកខ្មែរក្រហមនៅបន្ទាប់ពីចូលដល់ទីរួមខេត្តសៀមរាប ពួកគេមិនបានសម្លាប់ព្រះសង្ឃភ្លាមៗ មួយអង្គណាឡើយ តែផ្ទុយទៅវិញ ពួកគេបានប្រើប្រាស់ព្រះសង្ឃទាំងនោះ ដើម្បីបន្ថែមលើភាពស្រស់បំព្រងនៃពិធីអបអរនៃជោគជ័យដ៏ធំសម្បើមរបស់ពួកគេ ហើយដែលមានភាពអស្ចារ្យជាងអ្វីៗ ដែលធ្លាប់បានកើតឡើងក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាជាង ២០០០ ឆ្នាំ ។ វត្តទាំងអស់ក្នុងទីរួមខេត្តសៀមរាប រួមបញ្ចូលទាំងវត្តបូព៌ដ៏ស្រស់ស្អាត មិនត្រូវបានបំផ្លាញឡើយក្នុងកាលសម័យនោះ ។ យើងអាចស្តាប់ការរៀបរាប់របស់ព្រះតេជគុណ ទេព វង្ស បន្ថែមទៀត លើការកត់សម្គាល់ការកាត់ទោសពីបទប្រល័យពូជសាសន៍ កាលខែសីហា ឆ្នាំ ១៩៧៩ ថា ៖*

> « វត្តអារាមទាំង ៩ ក្នុងទីរួមខេត្តសៀមរាប ត្រូវគេយកទៅប្រើជាទីតាំងរក្សាសន្តិសុខតំបន់ ដោយសារតែវត្តខ្លះមានទីតាំងនៅជិតគុកចាស់ (ក្នុងករណីវត្តធម្មយុត្តិកនិកាយ) ឬក៏យកធ្វើជាបន្ទាយទាហាន និងជាទីកន្លែងសម្រាប់ហ្វឹកហ្វឺនកម្មាភិបាល (ដូចករណីវត្តព្រះព្រហ្មរតន៍) ។ រីឯវត្តខ្លះទៀត បានប្តូរទៅជាកន្លែងសម្រាប់បើកវគ្គបណ្តុះបណ្តាលជួសជុលយានយន្តរបស់កងទ័ព (ដូចក្នុងករណីវត្តស្វាយ) ។ ចំណែកឯវត្តមុនីសុវណ្ណ(១២) វត្តបូព៌ វត្តឥន្ទកោសា វត្តឥន្ទកោសី វិញ ត្រូវបានគេបោះបង់ចោល ហើយត្រូវស្មៅដុះពាសពេញ ។ មានការលេចឮថា វត្តទាំង ៩ នោះ ត្រូវបានប្រើប្រាស់ ឬផ្លាស់ប្តូរ គឺអាស្រ័យទៅលើការសម្រេចរបស់អ្នកដឹកនាំនីមួយៗ ក្នុងតំបន់(១៣) » ។

*ត្រឡប់ទៅនិយាយពីព្រះតេជគុណ ពុធ ប៉ុណ្ណ និងព្រះសង្ឃពីរអង្គផ្សេងទៀតវិញ ថ្ងៃមួយ ក្រុមព្រះអង្គបានទៅដល់សហករណ៍ថ្មីមួយ គេក៏ផ្សឹកក្រុមព្រះអង្គ និងប្រគល់ឲ្យនូវសម្លៀកបំពាក់ពណ៌ខ្មៅ ។ ការងាររចម្បងរបស់ព្រះសង្ឃទាំងបីអង្គ គឺមើលថែទានិងបសុបក្សីផ្សេងទៀត ព្រមទាំងមើលថែជ្រូកផងដែរ ។ នៅទីនោះ មានចំណីអាហារហូបគ្រប់គ្រាន់ ព្រោះលោកធ្វើការក្នុងកន្លែងផលិតអាហារ ។ ប្រាសាទទាំងឡាយដែលស្ថិតនៅតាមបណ្តោយស្ទឹងស្រែងក្នុងតំបន់នោះ មិនមាននរណាប៉ះពាល់ឡើយ តែរូបសំណាកព្រះពុទ្ធអង្គទាំងអស់ត្រូវបានបំផ្លាញ ។ រូបបដិមាមួយដែលយើងអាចមើលឃើញរហូតមកដល់ពេលបច្ចុប្បន្ន គឺរូបចម្លាក់ឈើមើលពីមុខរាងជាត្រីកោណដ៏ស្រស់ស្អាត ។*

*លោក ពុធ ប៉ុណ្ណ បាននិពន្ធចម្រៀងខ្លីមួយបទ សម្រាប់ឲ្យកុមារដែលចិញ្ចឹមទាជាមួយលោកផងដែរ ៖*

---

**(១២)** កំណត់បណ្ណាធិការ ៖ ហៅ វត្តគង់ម៉ុច ។

**(១៣)** ទំព័រទី ៧៧–៧៨, តុលាការបដិវត្តប្រជាជន ធ្វើនៅភ្នំពេញ ដើម្បីកាត់ទោសបទល្មើសប្រល័យពូជសាសន៍របស់បន ប៉ុល ពត – អៀង សារី ត្រង់ជំពូក « ចំលើយសាក្សី », មេធាវីកម្ពុជាមួយក្រុម គ.ស. ១៩៨០ ។ កំណត់បណ្ណាធិការ ៖ សម្រង់នេះ បានបកប្រែពីភាសាអង់គ្លេស ព្រោះរកអត្ថបទដើមជាខេមរភាសាពុំឃើញ ។

កុមារឃ្វាលទាមានប្រាំនាក់ មានតា ប៉ុណ្ណ ម្នាក់ជាអ្នកដឹកនាំ
កាធុប បហេ បហេ បហែ! លុះដល់វេលាថ្ងៃ នាំគ្នាធ្វើការ ។

នៅចុងបញ្ចប់នៃសម័យកម្ពុជាប្រជាធិបតេយ្យ លោក ពុង ប៉ុណ្ណ បានវិលទៅកាន់វត្តកេសរារាម វិញ ហើយលោកបានបួសសាជាថ្មីទៅតាមគន្លងព្រះពុទ្ធសាសនា ។ នៅពេលមកដំបូង លោកបាន ប្រទះឃើញថា វត្តនេះត្រូវបានគេប្តូរឲ្យទៅជាគុក នៅបន្ទាប់ពីគុកចាស់ដែលបន្សល់ពីសម័យ អាណានិគម ពេញទៅ ។ មានបន្ទប់ធ្វើទារុណកម្មមួយដែលអ្នកទោសនៅទីនោះ ត្រូវបានគេចងព្យួរ ជើងឡើងលើ ។ សាកសពអ្នកទោសប្រមាណជា ១០០ នាក់ បានកប់នៅក្បែរបរិវេណវត្ត ។ គេបាន គាស់ឆ្អឹងសាកសពទាំងនោះ យកទៅតម្កល់នៅទីកន្លែងអនុស្សាវរីយ៍មួយ ។ រាល់ពេលរំលឹកទិវាចង កំហឹង នៅថ្ងៃទី ២០ ឧសភា ក៏ជាឱកាសរំលឹកដល់វិញ្ញាណក្ខន្ធពួកគេ ។ កន្លែងប្រារព្ធពិធីរំលឹក អនុស្សាវរីយ៍ គ្រាន់តែជាខ្ទមឈើដែលទាមទារឲ្យមានការជួសជុល ហើយដែលមានឆ្អឹងសាកសពនៅ សេសសល់តិចតួចប៉ុណ្ណោះ ។ សព្វថ្ងៃនេះ មានព្រះសង្ឃប្រមាណជា ៥០ អង្គគង់នៅក្នុងវត្តនេះ ។

ផ្ទុយទៅវិញ មានកន្លែងរំលឹកការចងចាំធំជាងនេះ ដែលស្ថិតនៅក្បែរវត្តអដ្ឋិស្នូសាន[(១៤)] ដែល សាងសង់ថ្មីក្រោមការឧបត្ថម្ភរបស់អតីតកម្មាភិបាលខ្មែរក្រហម លោក ទៀ បាញ់ ហើយដែលបច្ចុប្បន្ន នេះ ជារដ្ឋមន្ត្រីក្រសួងការពារជាតិ ។ វិហារថ្មីនេះ សាងឡើងលើទីតាំង ដែលធ្លាប់ជាកន្លែងគេប្រើជា ការិយាល័យដ៏ធំមួយសាងដោយអ្នកជំនាញការចិន កាលពីអំឡុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៦០ នៅ ខណៈពេលដែលពួកគេកំពុងដំណើរការ ធ្វើការពង្រីកព្រលានយន្តហោះខេត្តសៀមរាប ។ កាលពេល នោះ ការឃោសនាអំពីបដិវត្តន៍វប្បធម៌ចិន ត្រូវបានគេព្យាយាមបញ្ជ្រាបទៅលើកម្មករខ្មែរ ។ លុះ ដល់សម័យកម្ពុជាប្រជាធិបតេយ្យ ទីតាំងនោះបានក្លាយទៅជាវាលពិឃាតនៅសៀមរាប ប្រៀបដូច ជើងឯកនៅជិតភ្នំពេញ ព្រោះគេបានដាក់ទោសឲ្យស្លាប់នូវអ្នកទោសក្នុងគុកចាស់សម័យអាណានិគម ដោយស្នាដៃអង្គការដែលបាននាំពួកគេទៅផ្តាច់ជីវិត ។ ដូច្នេះហើយបានជាមានរណ្តៅសាកសពជា ច្រើននៅទីនោះ ។ ស្តូបរំពុកវិញ្ញាណក្ខន្ធ មានរាងជាបួនជ្រុងធ្វើដោយផ្ទាំងកញ្ចក់នៅគ្រប់ជ្រុង ដែល អាចឲ្យអ្នកទេសចរអាចទស្សនាពីហេតុការណ៍ដ៏អាក្រក់របស់របបកម្ពុជាប្រជាធិបតេយ្យ ។

យើងក៏អាចអានពីការសរសេរពន្យល់ដែលមានចារនៅទីនោះថា ÷

> អដ្ឋិធាតុដែលលោកអ្នកបានឃើញនៅក្នុងស្តូបនេះ គឺជាឆ្អឹងដែលបានប្រមូលពីតំបន់ ក្បែរៗ នេះ ។ ពួកគេជាជនគ្មានកំហុស ដែលបានស្លាប់ក្រោមដៃដ៏សាហាវនៃរបប ប៉ុល ពល ចន្លោះឆ្នាំ ១៩៧៥–១៩៧៩ ។ យើងមិនមានថវិកាគ្រប់គ្រាន់ដើម្បីកសាងកន្លែងរំលឹក អនុស្សាវរីយ៍ឲ្យបានសមរម្យ ដើម្បីសម្តែងនូវការគោរពទៅដល់ជនគ្មានកំហុសទាំងនោះ ដែលត្រូវបានរបបផ្តាច់ការដ៏ឃោរឃៅសម្លាប់អស់ ១ ០០០ ០០០ នាក់ ក្នុងរយៈពេល ៤ ឆ្នាំ

---

**(១៤)** វត្តនេះបានដូរឈ្មោះជាច្រើនដង ។ នៅឆ្នាំ ១៩៨០ មានឈ្មោះថា វត្តសន្សំកុសល, នៅឆ្នាំ ១៩៨៣ មានឈ្មោះថា វត្តអដ្ឋិការាម, នៅឆ្នាំ ១៩៩៥ មានឈ្មោះថា វត្តអដ្ឋិស្នូសាន ហើយនិងតាំងពីឆ្នាំ ២០០៧ មានឈ្មោះថា វត្តទេពពោធិវង្ស ។ វត្តនេះក៏មានឈ្មោះសាមញ្ញថា វត្តថ្មីផងដែរ ។

នោះទេ ។ ពេលនេះ យើងអាចជួយសម្រាលការលំបាកដោយឧទ្ទិសទៅដល់ព្រលឹងជនរងគ្រោះតាមរយៈការជួយបរិច្ចាគជាថវិកា ។

## ៣– ការប្រព្រឹត្តិដ៏ពិសេសចំពោះក្រុមអ្នកអភិរក្ស

*ការអភិរក្សបានទទួលការអនុញ្ញាតឲ្យបន្តដំណើរការនៅប្រាសាទបាពួនរហូតដល់ថ្ងៃទី ២០ មករា ឆ្នាំ ១៩៧២ ស្របពេលដែលលោក ហ្វ្រង់ស្វា ប៊ីហ្សូត៍ បានរួចជីវិត ដោយសារអគ្គការ និង ឌុច បានដោះលែងគាត់នៅឱកាសបុណ្យណូអែល (គ្រីស្តម៉ាស់) ឆ្នាំ ១៩៧១ ។ សមាជិកនៃក្រុមអភិរក្សដែលបានជ្រើសរើសដោយសាលាបារាំងចុងបូព៌ា បានទទួលការស្វាគមន៍ដ៏ពិសេសនៅថ្ងៃដំបូងដែលពួកបដិវត្តទទួលបានជោគជ័យ ។ យោងទៅតាមលោក ពេជ កែវ*[១៥] *ជនជាតិបារាំងដែលសាលាបារាំងចុងបូព៌ាបានជ្រើសរើសឲ្យមកធ្វើការនៅចុងក្រោយគេ គឺលោក ម៉ារសែល លុយស៊ីយ៉ាំង ដែលទទួលបន្ទុកកាន់កាប់ខាងម៉ាស៊ីន និងការងារស្លូច ។ គាត់បានចាកចេញពីសៀមរាបនៅខែមករា ឆ្នាំ ១៩៧៥ ។ លោក ពេជ កែវ ក៏ដូចជាជនរួមជាតិរបស់គាត់ដទៃទៀតដែរ មានភាពសប្បាយរីករាយដោយបានឃើញសង្គ្រាមត្រូវបានបញ្ចប់ ហើយទន្ទឹមរង់ចាំចង់ឃើញអង្គរវត្តម្តងទៀត ដែលគាត់មិនបានឃើញចាប់តាំងពីខែមិថុនា ឆ្នាំ ១៩៧០ មកម្ល៉េះ ។ ពួកបដិវត្តបានចូលទីរួមខេត្តសៀមរាបនៅអំឡុងពេលថ្ងៃត្រង់ នៅខណៈដែលលោក ពេជ កែវ កំពុងស្នាក់នៅឯផ្ទះនៅឡើយ ។ នៅរាត្រីថ្ងៃទី ១៧ មេសា ១៩៧៥ មុនពេលពាក់កណ្តាលអធ្រាត្រ ពួកខ្មែរក្រហមមួយក្រុមបានចូលទៅក្នុងនាយកដ្ឋានអភិរក្ស ។ ពេលនោះមិនមានភ្លើងអគ្គិសនីទេ ។ ពួកគេបានចាប់លោក ពេជ កែវ និងសន្តិសុខរបស់គាត់ ចងនឹងក្រមា ។ ក្នុងពេលរាត្រីដ៏ងងឹតនោះ លោក ពេជ កែវ ត្រូវបានគេនាំយកទៅកាន់វិទ្យាល័យជយវរ្ម័នទី ២ ដែលស្ថិតនៅតាមបណ្តោយស្ទឹងសៀមរាប ហើយក៏ធ្លាប់ជាកន្លែងដែលគេប្រើធ្វើជាជំរំយោធានៃក្រុមរបស់លោកសេនាប្រមុខ លន់ នល់ ផងដែរ ។ ពួកគេបានប្រមូលយកអាវុធយុទ្ធភ័ណ្ឌទាំងអស់ ហើយរហូតដល់ម៉ោងប្រមាណជា ៤ ភ្លឺ ពួកគេក៏បង្ខំឲ្យក្រុមរបស់លោក ពេជ កែវ ជួយប្រមូលផងដែរ ។ នៅម៉ោង ៤ និង ៣០ នាទី ពួកគេបានអនុញ្ញាតលោកឲ្យត្រឡប់ទៅផ្ទះវិញ ។ ទាហានខ្មែរក្រហមមួយក្រុមរួចមកមួយក្រុមទៀត បានឆែកឆេរទីតាំងអភិរក្សគ្រប់ច្រកល្ហក ។ តែពួកគេមិនបានធ្វើអ្វីឡើយ ដោយគ្រាន់តែបានយកភ្លើងចន្លុះទៅជាមួយតែប៉ុណ្ណោះ ។*

*នៅព្រឹកថ្ងៃទី ១៨ ប្រធានដេប៉ាតឺម៉ង់ទាំងអស់ត្រូវបានកោះហៅឲ្យទៅសាលាខេត្ត ។ ទីនោះហើយជាទីដែលអង្គការបានបញ្ចេញមុខមាត់ពិតរបស់ខ្លួន ប៉ុន្តែ នៅតែមិនទាន់បញ្ចេញឈ្មោះឲ្យដឹងនៅឡើយ ។ អ្នកគ្រប់គ្នាត្រូវបានតម្រូវឲ្យចាកចេញពីផ្ទះក្នុងអំឡុងពេលដាក់លាក់មួយ ដើម្បីជួយបង្កបង្កើនផលិតផលជូនជាតិ ។ ពួកមន្ត្រីយោធា ត្រូវបានគេហៅឲ្យទៅប្រមូលផ្តុំដំបូងគេ និងបន្ទាប់មកក៏ត្រូវជម្លៀសចេញទៅ ។ លោក ពេជ កែវ ត្រូវបានគេសួរនាំពីទីកន្លែងរបស់ «បារាំងធំ» នោះ ហើយគាត់ក៏បានឆ្លើយតបថា លោក ហ្គ្រោស៍លីយ៉េរ៍ បានត្រឡប់ទៅប្រទេសបារាំងវិញហើយ គឺរូបគាត់ (ពេជ កែវ) ផ្ទាល់ជាអ្នកទទួលបន្ទុកគ្រប់គ្រងនាពេលនេះ ។ ជាក់ស្តែង គឺរូបគាត់ជាអ្នកកាន់កូន*

---

**(១៥)** សម្ភាសន៍នៅថ្ងៃទី ១៣ មិថុនា ២០០៤ ។

សោបន្ទប់ដែលជាឃ្លាំងខាងក្នុងកន្លែងអភិរក្សសម្រាប់រក្សានូវក្បាច់ចម្លាក់និងរូបបដិមាសម័យអង្គរជាច្រើន ។ ដោយបានយល់ច្បាស់អស់ហើយ អគ្គការក៏បានបញ្ជាឲ្យលោក ពេជ កែវ និងក្រុមរបស់គាត់ ដោយរួមទាំងក្រុមគ្រួសាររបស់ពួកគេផង សរុបទាំងអស់ប្រមាណជា ៥៧០ នាក់ បន្តធ្វើការអភិរក្សទៅតាមតួនាទីរៀងៗខ្លួន ក្នុងដំណើរការសាងសង់ ដែលមានពេលប្រមាណជាពីរសប្តាហ៍ ។ ពួកគេមិនបានទទួលការអនុញ្ញាតឲ្យចេញក្រៅទេ ហើយពួកគេអាចរស់បាន ក៏ដោយសារតែបានរក្សាទុកប្រហុក ត្រីងៀត និងអាហារផ្សេងៗ ទៀត ដែលមានលក្ខណៈល្អបំផុតសម្រាប់ទុកបរិភោគបានយូរ ។ ពួកគេមិនអាចចាកចេញពីទីតាំងនេះបានទេ ព្រោះត្រូវស្ថិតនៅក្រោមការឃ្លាំមើលពីសំណាក់ទាហានខ្មែរក្រហមក្មេងៗ អាយុប្រមាណ ១២ ឆ្នាំ ដែលមានចរិតកាចសាហាវជាងខ្លែគ្គួតទៅទៀត ។ នៅពេលបន្ទាប់មក គឺនៅដើមខែឧសភា មានឡានទ្រុងមកដឹកជញ្ជូនពួកគេទាំងអស់ ទៅដាក់នៅក្បែរប្រាសាទលលៃក្នុងតំបន់រលួស ។ អ្នកទាំងនោះត្រូវបានបញ្ជូនទៅក្នុងវត្តថ្មីនៅរលួស ។ នៅទីនោះ គេបានផែកអត្តសញ្ញាណរបស់អ្នកទាំងនោះ ចាប់តាំងពីកម្មករធម្មតារហូតដល់មេក្រុមអ្នកបញ្ជាម៉ាស៊ីន អ្នករៀបពុម្ពអក្សរ និងលេខាធិការ ។ បន្ទាប់មក ពួកគេត្រូវបានគេបែងចែកឲ្យនូវដីមួយក្បាល ដើម្បីធ្លារសម្អាត និងសង់ខ្ទមសម្រាប់រស់នៅ ។

បន្តិចក្រោយមក ស្ថានភាពក្រុមគ្រួសារនៃអ្នកអភិរក្សទាំងនោះ មានភាពប្រសើរឡើង ។ ដោយចាត់ទុកដូចជាប្រជាជនមូលដ្ឋាន ពួកគេត្រូវបានបញ្ជូនឲ្យទៅរស់នៅក្នុងភូមិប្រមាណជាប្រាំមួយដែលស្ថិតនៅជាភូមិដែលមានសហករណ៍តូចៗ នៅឡើយ និងមិនអាចពង្រីកជំក្លាយជាសហករណ៍ធំថ្នាក់ឃុំបាន ដូចមាននៅទូទាំងប្រទេសបាននោះទេ ។ បញ្ហានេះបានជួយពួកគេឲ្យឆ្លងពេលវេលាដ៏គួរឲ្យភ័យខ្លាចនៃឆ្នាំ ១៩៧៦, ១៩៧៧ និង ១៩៧៨ ។ ប្រជាជនក្នុងតំបន់រលួស ប្រាសាទបាគង ត្រូវបានជម្លៀសជាបណ្តោះអាសន្នទៅកាន់ភាគខាងជើង ហើយបន្ទាប់មក ក៏ជម្លៀសត្រឡប់មកវិញ ។ ក្រុមគ្រួសារនៃអតីតអ្នកអភិរក្សត្រូវបានពង្រាយទៅក្នុងសហករណ៍ភូមិមួយចំនួននៃភូមិដែលស្ថិតនៅក្បែរៗ នោះ ។ យោងទៅតាមលោក ពេជ កែវ និងជំនួយការរបស់គាត់គឺលោក កុយ ចែម ប្រមុខគ្រួសារទាំងអស់នៃអ្នកអភិរក្សបាននៅរស់ លើកលែងតែកូនៗ របស់ពួកគេតែប៉ុន្មាននាក់ប៉ុណ្ណោះ ដែលប្រហែលជាបានស្លាប់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ពួកគេត្រូវបានបញ្ជូនទៅកាន់ភូមិផ្សេងៗ នៅស្រុកដូនទាវ ទៅកាន់ភាគនិរតីនៃផ្លូវជាតិលេខ ៦ គឺភូមិតាប្រាក់ មិនឆ្ងាយប៉ុន្មានពីផ្សាររលួស ទៅកាន់ភាគខាងត្បូងនៃផ្លូវជាតិលេខ ៦ គឺភូមិដូនទំ និងបញ្ជូនទៅភូមិបន្ទាយបុស្ស៊ី ចម្ងាយប្រមាណជា ៣ ទៅ ៤ គ.ម. ខាងត្បូវផ្លូវជាតិលេខ ៦ ឆៀងខាងត្បូងនៃភូមិកំពង់ថ្កូវ ។ នៅទីនោះមានត្រីសម្រាប់ផ្គត់ផ្គង់តម្រូវការបានគ្រប់គ្រាន់សម្រាប់ក្រុមអ្នកអភិរក្ស ពេញមួយសម័យកម្ពុជាប្រជាធិបតេយ្យ ។ ទីនោះគឺជាតំបន់ដែលមានលក្ខណៈអំណោយផល មានចម្ងាយប្រមាណជា ២ ទៅ ៥ គ.ម. ខាងត្បូងផ្លូវជាតិលេខ ៦ ។ ពួក ១៧ មេសា ដែលបញ្ជូនទៅពីភ្នំពេញ និងពីទីក្រុងផ្សេងៗទៀតទាំងអស់ ត្រូវបានបញ្ជូនទៅកាន់ភាគខាងត្បូងនៃឃុំអង្គ្រង (៥ គ.ម. នៅភាគឦសានផ្លូវជាតិលេខ ៦) ។ ដូចនេះ វាមានន័យថា ក្នុងពួក ១៧ មេសា មិនបានបញ្ជូនឲ្យទៅរស់នៅជាមួយនឹងក្រុមអ្នកអភិរក្សឡើយ ។

នៅក្នុងសហករណ៍ភូមិទាំងនោះ អតីតអ្នកអភិរក្សទាំងអស់មិនបានរង គ្រោះដោយការអត់ឃ្លាននោះឡើយ ។ នៅពេលដែលពួកគេត្រូវការអង្ករ ពួកគេស្នើសុំដោយសរសេរជាលិខិត ឬក៏ទៅយកពីកន្លែងផ្សេងមក ។ ឧទាហរណ៍ ពួកគេយកត្រីពីកំពង់ភ្លុក ជាតំបន់ស្ថិតនៅបឹងទន្លេសាប ទៅដូរយកស្រូវនៅឯស្រុកបន្ទាយស្រី ។ នេះគឺស្ថានភាពមួយដែលមានភាពខុសគ្នាយ៉ាងខ្លាំងទៅនឹងសហករណ៍ឯទៀត ។ ជាមធ្យម សហករណ៍មួយមានគ្នាប្រមាណពី ១០ ទៅ ៣០ គ្រួសារ ដែលហូបអាហាររួមគ្នា ។ ស្របទៅនឹងនេះ ដូចអំណះអំណាងរបស់លោក ពេជ កែវ, កុយ ថែម, និង ឆាយ សុទ្ធ[១៦] (ជាជាងចម្លាក់ថ្ម) ពួកគេត្រូវបានគេចាត់ទុកដូចជាប្រជាជនចាស់ ឬប្រជាជនមូលដ្ឋានដែរ ។ ពួកគេស្ទើរតែទទួលបានការព្យាបាលជំងឺធម្មតា ព្រោះនៅជិតបរិវេណដែលគេរស់នៅចម្ងាយប្រមាណជា ៤ គ.ម. ខាងត្បូងផ្លូវជាតិលេខ ៦ និងផ្សាររលួស មានមន្ទីរពេទ្យគំរូគណៈកម្មការមជ្ឈិម សម្រាប់ហ្វឹកហ្វឺនគ្រូពេទ្យបដិវត្ត ។ ក្រុមគ្រួសារនៃអ្នកអភិរក្សអាចទៅមន្ទីរពេទ្យនោះ ដើម្បីព្យាបាលនិងសម្រាលកូន ។ នៅទីនោះ មានគ្រែល្អសមរម្យដែលគេយកមកពីអតីតមន្ទីរពេទ្យសៀមរាប ។ គ្រូបង្ហាត់នៅទីនោះ ធ្លាប់ធ្វើជាវេជ្ជបណ្ឌិតក្នុងសម័យមុន ហើយបានទៅរស់នៅទីនោះ ។ ចំពោះថ្នាំពេទ្យ គឺប្រើប្រាស់ថ្នាំបុរាណខ្មែរ ។ មានគ្រែ ១០ ក្នុងមួយបន្ទប់ ហើយអ្នកជំងឺអាចយកកន្ទេល មុងទៅជាមួយ ។ អាហារមានភាពបរិបូរជាងនៅក្នុងសហករណ៍ គេចែកបាយឬបបរខាប់ឲ្យអ្នកជំងឺ[១៧] ។

មានទម្រង់នៃការអប់រំមួយចំនួន ដែលកុមារត្រូវបានគេបង្រៀនក្រៅម៉ោង ដើម្បីឲ្យចេះអាននិងសរសេរ ។ តែពួកគេក៏ត្រូវរៀនច្រៀងចម្រៀងបដិវត្ត និងចំណាយពេលជាច្រើនម៉ោងក្នុងមួយថ្ងៃធ្វើជីដោយលាយស្លឹកឈើជាមួយនឹងលាមកមនុស្សផង ដូចគ្នាទៅនឹងកន្លែងឯទៀតទូទាំងប្រទេសកម្ពុជា ។ ជាមួយនឹងការប្រព្រឹត្តិយ៉ាងពិសេសនេះ ថ្នាក់ដឹកនាំខ្មែរក្រហមនៅមិនទាន់រួចរាល់នៅឡើយមកដល់ដើមរដូវប្រាំងឆ្នាំ ១៩៧៨ ក្នុងការបញ្ជូនពួកនេះឲ្យត្រឡប់ទៅកាន់សៀមរាប និងតំបន់បុរាណដ្ឋានវិញ ដើម្បីបន្តការងារនៅតាមប្រាសាទ ។ របបដំឡូតលេលានេះនៅមិនទាន់គិតឃើញវិធានការដ៏សមស្របនិងជាក់លាក់មួយនៅឡើយទេ តែគេយកចិត្តទុកដាក់ជាសំខាន់តែទៅលើការដឹករំលើងខ្មាំងដែលពិតប្រាកដ និងអ្នកដែលគេសង្ស័យ ។

## គ. តំបន់បុរាណដ្ឋាន និងភ្ញៀវបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ក្នុងនាមជារដ្ឋផ្តាច់ការ អង្គការដ៏អាថ៌កំបាំងសង្ឃឹមថា អាចគ្រប់គ្រងលើរាល់ចំណុចទាំងអស់ក្នុងសង្គម ក៏ដូចជាជីវិតឯកជន ប៉ុន្តែវាគឺជារឿងដែលមិនអាចទៅរួចឡើយ ។ ជាលទ្ធផល សង្គមមួយនេះក្លាយទៅជាសង្គមដែលពោរពេញទៅដោយបដិវាទកម្ម និងការបោកប្រាស់ ។ ឧទាហរណ៍ នៅខណៈពេលដែលមានគណៈប្រតិភូបរទេសកាន់តែច្រើនឡើងៗ ទៅទស្សនាប្រាសាទដ៏ស្រស់ស្អាត ពួកគេត្រូវធ្វើ

(១៦) កើតឆ្នាំ ១៩៤៤, សម្លាសនៅថ្ងៃទី ១៥ កុម្ភៈ ២០០២ ។ សមាជិកគ្រួសាររួមទាំងកូនទាំង ៧ នាក់របស់គាត់ គឺនៅរស់ទាំងអស់ ។

(១៧) ព័ត៌មានផ្តល់ឲ្យដោយលោក កុយ ថែម កាលពីថ្ងៃ ២៤ មករា ២០០១ និងបញ្ជាក់បន្ថែមដោយលោក ពេជ កែវ កាលពីថ្ងៃ ១៣ មិថុនា ២០០៤ ។

ដំណើរកាត់តាមផ្លូវជាតិលេខ ៦ មកពីទិសខាងលិច និងមកពីខាងស៊ីសូផុន ដែលនៅតាមដងផ្លូវ ពោរពេញដោយសាកសពនៃជនរងគ្រោះរបស់អគ្គការដ៏កំណាច រាប់ពាន់នាក់ ត្រូវបានសម្លាប់នៅពេលពាក់កណ្តាលអធ្រាត្រ ហើយត្រូវបានកប់ក្នុងរណ្តៅរួមយ៉ាងស្ងៀមស្ងាត់ ។ ឯកអគ្គរដ្ឋទូត និងអ្នកតំណាងនៃបក្សដៃគូបរទេស បានទទួលការស្វាគមន៍យ៉ាងអ៊ឹកធឹកនៅឯសណ្ឋាគារហ្គ្រាង់អូតែលអង្គរ ខណៈដែលអ្នកទោសរាប់ពាន់នាក់ត្រូវបានឃុំនៅចម្ងាយប្រមាណ ១០០ ម៉ែត្រភាគខាងត្បូងក្នុងអតីតគុកសល់ពីសម័យអាណានិគម ដែលត្រូវគេប្រែទៅជាមណ្ឌលឃុំឃាំងធំជាងគេនៅទូទាំងតំបន់ភាគខាងជើង ។

តំបន់បុរាណដ្ឋានអង្គរ មិនមានការកាប់សម្លាប់ទេ លើកលែងតែនៅភូមិខ្វះក្នុងឃុំព្រះដាក (ប្រដាក) ក្បែរប្រាសាទប្រែរូបក្នុងស្រុកបន្ទាយស្រីចេញ ។ យោងទៅតាមឈ្មោះ តូច ឈន់[(១៨)] ដែលជាមេឃុំព្រះដាក ក្នុងឆ្នាំ ១៩៩១ បានឲ្យដឹងថា មានមន្ទីរឃុំឃាំងចំនួនបួននៅក្នុងស្រុកនេះ ÷

គុកលេខ ១ – ព្រះដាក

គុកលេខ ២ – ភូមិឃុនព្រហ្ម ស្ថិតក្នុងឃុំឃុនរាម គឺស្ថិតនៅក្នុងសាលារៀនចាស់មួយក្នុងព្រៃប្រមាណ ១៩ គ.ម. ពីឃុំព្រះដាក និង ៤ គ.ម. នៅខាងជើងប្រាសាទបន្ទាយស្រី ។

គុកលេខ ៣ – វត្តព្រៃ (ចម្ងាយពី ៦ ទៅ ៧ គ.ម. នៅខាងជើងប្រាសាទបន្ទាយស្រី) ស្ថិតក្នុងឃុំខ្នារសណ្តាយ ។

គុកលេខ ៤ – វត្តត្បែង (ស្ថិតនៅចម្ងាយប្រមាណ ៨–៩ គ.ម. ពីប្រាសាទបន្ទាយស្រី ទៅភាគឦសាន) ។ នៅទីនោះ គឺជាកន្លែងតែមួយគត់ ដែលគេសម្លាប់អ្នកទោស ដោយមិនបានឃុំឃាំងក្នុងវត្តឲ្យលើសពីពីរឬបីថ្ងៃឡើយ ។

មានរណ្តៅសាកសពមួយចំនួននៅក្បែរប្រាសាទប្រែរូប ដែលជាកន្លែងអ្នកទោសត្រូវបានសម្លាប់និងកប់នៅទីនោះ ។ អ្នកទោសទាំងនោះត្រូវបានគេនាំយកពីទីរួមខេត្តសៀមរាបទៅ ។ ពួកគេ ដាបឋម ត្រូវបានគេនាំយកទៅឃុំឃាំងនៅក្នុងឃុំព្រះដាក ហើយបន្ទាប់មក ទើបយកទៅសម្លាប់នៅក្បែរប្រាសាទប្រែរូប ។ យើងអាចស្វែងរកសាក្សីនៅក្នុងភូមិនេះ ដើម្បីបញ្ជាក់ពីហេតុការណ៍នេះ ។

គុកលេខ ១ នៅវត្តព្រះដាក គ្រាន់តែជាគុកក្នុងឃុំមួយ ស្ថិតនៅខាងកើតប្រាសាទប្រែរូប នៅតាមផ្លូវឆ្ពោះទៅកាន់បន្ទាយស្រីនិងភ្នំគូលែន ។ យោងទៅតាមអតីតកម្មាភិបាលខ្មែរក្រហមឈ្មោះ មឿន រ៉ឺន[(១៩)] ហើយក៏ជាអតីតប្រធានសហករណ៍ផងដែរនោះ បានឲ្យដឹងថា ខ្មែរក្រហមបានមកដល់ព្រះដាកនេះតាំងពីឆ្នាំ ១៩៧៣ ហើយបានជម្លៀសប្រជាជនមកពីភូមិស្រះស្រង់ ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីខាងត្បូងបរិវេណតំបន់បុរាណដ្ឋាន ឲ្យមករស់នៅទីនេះ ។ លោក មឿន រ៉ឺន បានបញ្ជាក់ថា អ្នកសម្លាប់មនុស្សនៅទីនោះ គឺជាអ្នកភូមិរបស់គាត់ឈ្មោះ តាបុត្រ ។ តាបុត្រនេះបានពិឃាតមនុស្សប្រមាណពីមួយទៅបីគ្រួសារក្នុងមួយថ្ងៃ ។ វាបានរត់គេចនៅពេលបន្ទាប់ ។ មានរណ្តៅសាកសពប្រមាណជា ២០ នៅម្តុំប្រាសាទប្រែរូប ។ អ្នកភូមិបានប្រមូលលលាដ៍ក្បាលដាក់មួយកន្លែង ដើម្បីរៀបចំពិធីបុណ្យសពមួយ ។ ក្នុងចន្លោះឆ្នាំ ១៩៨០–៨១ ប្រជាជននៅទីនោះបាននាំគ្នា

---

(១៨) កើតឆ្នាំ ១៩៣១, សម្លាប់កាលពីថ្ងៃ ២៣ កក្កដា ១៩៩១ នៅភូមិព្រះដាក ។

(១៩) កើតឆ្នាំ ១៩៤៧, សម្ភាសនៅថ្ងៃទី ២៣ កក្កដា ១៩៩១ ។

ដីករុករកសាកសពញាតិមិត្តរបស់ពួកគេ និងរកមាស ។ មានដើមឈើខ្ពស់ៗ ជាច្រើន ទំនងជាមានព្រៃនៅទីនោះ ។ គេបានរៀបចំពិធីបុណ្យសពមួយនៅក្បែរប្រាសាទប្រែរូប ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ ។

យោងទៅតាមឈ្មោះ យឿន យឿម[២០] ដែលជាលេខាធិការឃុំ បានឲ្យដឹងថា វត្តក្នុងភូមិនោះ គេប្រើប្រាស់ធ្វើជាគុកនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៨ ។ ព្រះវិហារដែលគេយកធ្វើជាគុកកាលនោះ ក្នុងឆ្នាំ ១៩៧៨ វត្តនិងសាលាឆាន់នៅទីនោះ ត្រូវបានបំផ្លាញ ហើយផ្ទះរបស់អ្នកភូមិត្រូវបានយកប្រើជាគុកជំនួស ។ ផ្ទះនោះមកដល់សព្វថ្ងៃនេះ ត្រូវបានបំផ្លាញទៅហើយ ។ នៅទីបរិវេណវត្តព្រះដាក នាពេលបច្ចុប្បន្ននេះ គេបានប្រាប់ខ្ញុំឲ្យដឹងថា អតីតវត្តដ៏ធំនេះ ត្រូវបានគេប្រើម៉ាស៊ីនឈូសដីឲ្យរាបស្មើ កាលពីឆ្នាំ ១៩៧៨ ។ នៅក្នុងវត្តនេះ កាលនោះ មានរូបគំនូរបុរាណ ដូចមាននៅក្នុងវត្តបូព៌ក្នុងទីរួមខេត្តសៀមរាបដែរ ។ សព្វថ្ងៃ មាននៅសល់តែជើងសសរគ្រឹះប៉ុណ្ណោះ ។ រូបសំណាកព្រះពុទ្ធទាំងឡាយ ត្រូវបានគេយកទៅកប់ក្នុងដី ។ តែក៏មានសេសសល់រូបសំណាកធ្វើពីឈើខ្លះផងដែរ ។ កាលពេលដែលវត្តនេះត្រូវបានគេប្រើប្រាស់ធ្វើជាគុក មានអ្នកទោសជាប់ក្នុងចំណោមប្រមាណជា ២០០ ទៅ ៣០០ នាក់ ។ អ្នកទាំងនេះ ភាគច្រើន ជាអ្នក ១៧ មេសា ដែលគេនាំមកពីសៀមរាប បាត់ដំបង និងអ្នកទោសជាច្រើនទៀត គឺមកពីភ្នំពេញ ។

មិនមានអ្នកមកទស្សនាណាមួយ មកមើលឲ្យឆ្ងាយហួសពីប្រាសាទបាយ័នឡើយ ។ ពេញមួយរបបដែលមានអាយុដ៏ខ្លីនេះ អ្នកមកទស្សនាប្រាសាទអង្គរវត្តភាគច្រើន ជាគណៈប្រតិភូចិន ដែលអ្នកទាំងនោះភាគច្រើនប្រាថ្នាថតរូបនៅខាងមុខផ្ទាំងជើងល្បឿនល្បាញមួយនេះ ។ ឧបសគ្គនោះ គឺស្ថិតនៅត្រង់ថា គេពិបាកនឹងទៅដល់ទីនោះតាមផ្លូវពីភ្នំពេញ ។ ផ្លូវនោះមិនបានទទួលការជួសជុលចាប់តាំងពីពេលមានសង្គ្រាម និងពេលដែលព្រលានយន្តហោះសៀមរាបមិនមានដំណើរការរហូតដល់ចុងឆ្នាំ ១៩៧៨ មកម្ល៉េះ ។ ប៉ុន្តែ យើងក៏ថ្លែងអំណរគុណចំពោះជំនួយ និងអ្នកជំនាញការពិសេសរបស់ចិន ដែលបានជួសជុលធ្វើថ្មីនូវផ្លូវរថភ្លើងពីរខ្សែ ជួយសម្រួលការដឹកជញ្ជូនស្រូវរាប់ពាន់តោន ឆ្ពោះទៅកាន់កំពង់ផែដ៏ធំនៅកំពង់សោម និងរថភ្លើងអាចរត់ទៅទិសខាងលិចដល់ស៊ីសូផុន ដែលជាតំបន់ផលិតស្រូវដ៏សំខាន់ជាងគេក្នុងប្រទេសកម្ពុជា ។ ភ្ញៀវសំខាន់ៗ របស់កម្ពុជាប្រជាធិបតេយ្យ (ជាទូទៅ ជាកម្មាភិបាលមកពីបណ្ដាប្រទេសកុម្មុយនិស្ត ក៏ដូចជាតំណាងបក្សតូចៗ នៅបស្ចិមប្រទេស ដែលមាននិន្នាការទៅរកលទ្ធិម៉ៅ) បានជិះរថភ្លើងដែលបើកក្នុងល្បឿនយឺតៗ ឆ្ពោះទៅស៊ីសូផុន ហើយអ្នកទាំងនោះបានស្នាក់នៅខុសគ្នាដាច់ឆ្ងាយពីប្រជាជនសាមញ្ញ ដែលកំពុងជួបការលំបាក ។ ក្នុងដំណាក់កាលចុងក្រោយនៃការមកទស្សនា គឺធ្វើឡើងដោយឡាន ហើយអ្នកមកទស្សនា ដែលធ្លាប់តែត្រូវបានគេធ្វើឲ្យងងឹតមិនអាចមើលអ្វីឃើញនោះ តែពេលនេះ ពួកគេអាចមើលឃើញនូវទិដ្ឋភាពពិតខ្លះៗ ហើយ ។

នៅថ្ងៃទី ២៩ កុម្ភៈ ឆ្នាំ ១៩៧៦ ដើម្បីជាការព្រមានទៅដល់មតិអន្តរជាតិ ប្រឆាំងនឹងនយោបាយវាតទីនិយម និងបទឧក្រិដ្ឋរបស់សហរដ្ឋអាមេរិក ឯកអគ្គរដ្ឋទូតមកពីប្រទេសស៊ុីស ហ្សំប៊ី អេហ្ស៊ីបទុយនីស៊ី អាហ្វហ្គានីស្ថាន និងប៉ាឡេស្ទីន បានទទួលសេចក្ដីអញ្ជើញឲ្យធ្វើដំណើរពីភ្នំពេញទៅទស្សនា

(២០) កើតឆ្នាំ ១៩៥៦, សម្ភាសនៅថ្ងៃទី ២៣ កក្កដា ១៩៩១ ។

*នៅខេត្តសៀមរាប «ក្នុងគោលបំណងចង់ឲ្យអ្នកទាំងនោះបានមើលឃើញរណ្ដៅបណ្ដាលមកពីការទម្លាក់គ្រាប់បែករបស់អាមេរិក ដែលជាសត្រូវពោរពេញដោយអំណាច» ។ តាមការពិត ជារណ្ដៅបណ្ដាលមកពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំងតាំងពីមុនខែសីហា ឆ្នាំ ១៩៧៣ មកម្ល៉េះ ។ នៅខែកញ្ញា ឆ្នាំ ១៩៧៦ ជាដាលើកដំបូងបង្អស់រាប់ចាប់តាំងពីការចាប់ផ្ដើមសង្គ្រាម ខែមីនា ឆ្នាំ ១៩៧០ មកដែលឯកអគ្គរដ្ឋទូតមកពីសេនេហ្គាល់ ហ្គីនេខាងលិច និងអេហ្ស៊ីប បានទៅទស្សនាប្រាសាទមួយចំនួន*[២១] *។ លោក ចេន យ៉ុង-គួយ សមាជិកមួយរូបនៃមជ្ឈិមបក្សកុម្មុយនិស្តចិន បានធ្វើដំណើរទស្សនាប្រទេសកម្ពុជាចំនួនពីរសប្ដាហ៍ អមដំណើរដោយ ប៉ុល ពត ផ្ទាល់ នៅពេលទៅទស្សនានៅសៀមរាប ហើយដែលជាពេលចាប់ផ្ដើមនៃដំណើរ ២ សប្ដាហ៍នោះក្នុងខែធ្នូ ឆ្នាំ ១៩៧៧ ។ គាត់បានផ្ដោយនូវពាក្យសរសើរមិនដាច់ពីមាត់នូវអ្វីៗ ដែលគាត់បានឃើញក្នុងប្រទេសនេះ ។ ប្រមុខរដ្ឋនៃប្រទេសរូម៉ានី លោក នីកូឡៃ ចូវសេស្កូ គឺជាប្រមុខរដ្ឋទីពីរ ដែលបានមកទស្សនាកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីលោក នេ វិន នៃប្រទេសភូមា ។ ក្នុងពេលការមកទស្សនារបស់ពួកគាត់កាលពីថ្ងៃទី ២៩ ខែមីនា ឆ្នាំ ១៩៧៨ នោះ លោកបានទទួចឡើងកំពូលប្រាសាទអង្គរវត្តជាមួយនឹងករិយាឈ្មោះ អេឡេណា បើទោះជាកំពុងមានភ្លៀងដែលធ្វើឲ្យកាំជណ្ដើរប្រែរអិលក៏ដោយ ។*

*ក្នុងឆ្នាំ ១៩៧៨ ប្រទេសកម្ពុជាបានចាប់ផ្ដើមអនុញ្ញាតឲ្យអ្នកកាសែតបរទេស និងគណៈប្រតិភូរបស់គណៈបក្សដែលមាននិន្នាការម៉ៅនិយម នៅទូទាំងពិភពលោក ធ្វើដំណើរចូលមក ។ ឧទាហរណ៍មានការពិព័ណ៌នាដ៏ខ្វីមួយ ដោយ «អ្នកតំណាងនៃក្រុមអ្នកកាសែតហុងកុង» ៖*

> « អ្នកកាសែតទាំងពីរ បានចាកចេញពីភ្នំពេញនៅថ្ងៃទី ៤ កញ្ញា (១៩៧៨) ដោយរថភ្លើងឆ្ពោះទៅកាន់ស៊ីសូផុន និងបន្ទាប់មក ក៏បន្តដំណើរទៅទីក្រុងសៀមរាបដោយឡាន ។ នៅខណៈដែលស្ថិតនៅសៀមរាប ពួកគាត់បានទៅទស្សនាទំនប់ស្ទឹងសៀមរាប និងបារាយណ៍ទឹកថ្លា ប្រាសាទបាយ័ន ប្រាសាទអង្គរវត្ត ខ្សែក្រវាត់ការពារក្នុងតំបន់អង្គរដែលបង្ហាញពីទាហានបដិវត្តកម្ពុជាដ៏អង់អាចក្នុងអំឡុងនៃពេលធ្វើសង្គ្រាមរំដោះជាតិ និងរណ្ដៅនៃការទម្លាក់គ្រាប់បែក ដែលបង្ហាញពីបទឧក្រិដ្ឋរបស់ចក្រពត្តិអាមេរិកចំពោះកម្ពុជាប្រជាធិបតេយ្យ »[២២] ។

*ស្រដៀងគ្នានេះ នៅប៉ុន្មានថ្ងៃក្រោយមក* « គណៈប្រតិភូបក្សពលករកុម្មុយនិស្តម៉ាក្ស-ឡេនីន នៃប្រទេសន័រវ៉េស ដឹកនាំដោយប្រធានបក្ស សមមិត្ត ប៉ាល ស្ទៃហ្គាន (Pal Steigan) នៅថ្ងៃទី ២៤ កញ្ញា (១៩៧៨) មកធ្វើទស្សនកិច្ចមកតំបន់សៀមរាប–អង្គរ ដោយធ្វើដំណើរកាត់តាមភូមិភាគពាយ័ព្យ ។ ភ្ញៀវដ៏រួសរាយទាំងនោះ បានចាកចេញពីភ្នំពេញ

---

**(២១)** សូមមើលអត្ថបទរបស់លោក សាស្ហា ស្ហែរ (Sacha Sher) “le Parallèle éminemment douteux entre l’*Angkar* révolutionnaire et Angkor” « [ភាពស្របគ្នាគួរឲ្យសង្ស័យជាទីបំផុតរវាងអង្គការបដិវត្តនិងអង្គរ] » នៅក្នុង **អាសៀអានី** (Aséanie) **មនុស្សសាស្ត្រនៅអាស៊ីអាគ្នេយ៍** បាងកក ខែមិថុនា ២០០៣ ទ. ២៥ ហើយនិងកាសែត **ឡឺម៉ុងដ៍** *(Le Monde)* ២១ កញ្ញា ១៩៧៦ ។

**(២២)** ផ្នែកព័ត៌មានផ្សព្វផ្សាយពីបរទេស ថ្ងៃទី ២៦ កញ្ញា ១៩៧៨, អាស់ ១ ។ កំណត់បណ្ណាធិការ ៖ សម្រង់នេះ ត្រូវបានបកប្រែពីភាសាអង់គ្លេស ព្រោះរកអត្ថបទដើមជាខេមរភាសាពុំឃើញ ។

ហើយបន្តដំណើរទៅស៊ីសុផុនដោយរថភ្លើង និងបន្ទាប់មក ធ្វើដំណើរទៅកាន់ក្រុងសៀមរាបដោយឡាន ។ ក្នុងតំបន់សៀមរាប–អង្គរ ភ្ញៀវដ៏រាក់ទាក់ទាំងនោះបានទៅទស្សនាបារាយណ៍ទឹកថ្លា ប្រាសាទតាកែវ ប្រាសាទបាយ័ន និងប្រាសាទអង្គរវត្ត »[(២៣)] ។

*គោលបំណងនៃការធ្វើទស្សកិច្ចនេះ គឺដើម្បីបង្ហាញភ្ញៀវបរទេសទាំងនោះឲ្យស្ងប់ស្ងែងនូវស្នាដៃរបស់ប្រជាជនកម្ពុជា ដែលជាអ្នកធ្លាប់មានប្រពៃណីដ៏ផូរផង់យូរលង់មកហើយ ក្នុងនាមជាអ្នកឧស្សាហ៍ព្យាយាម និងក៏ជាពូជសាសន៍ដែលមានការច្នៃប្រឌិតប្រកបដោយទេពកោសល្យ ហើយប្រាសាទអង្គរវត្តគឺជានិមិត្តរូបនៃទេពកោសល្យនេះ*[(២៤)] *។ ម្យ៉ាងទៀត គោលបំណងនៃដំណើរទេសចរណ៍ដែលបង្កប់នូវការឃោសនាទាំងនេះ ធ្វើឡើងនៅដំណាក់កាលចុងក្រោយនៃរបបនោះ គឺចង់បញ្ឈប់នូវពាក្យចចាមអារ៉ាមនៅបរទេសអំពីបទឧក្រិដ្ឋដ៏ធំប្រឆាំងនឹងមនុស្សជាតិ ដែលប្រព្រឹត្តឡើងដោយបដិវត្តន៍របស់អង្គការ ។ ហើយវាទំនងជាទទួលបាននូវជោគជ័យ បើយោងទៅតាមរបាយការណ៍នៃការមកទស្សនារបស់គណៈប្រតិភូបារាំង ដឹកនាំដោយសមមិត្ត ហ្សាក់ ហ្សៀរកេត់* (Jacques Jurquet) *ដែលជាអគ្គលេខាធិការនៃបក្សកុម្មុយនិស្តម៉ាក្ស–ឡេនីនដ៏តូចមួយក្នុងប្រទេសបារាំង ÷*

« ភ្ញៀវទាំងនោះត្រូវបានគេនាំទៅមើលស្នាដៃសិល្បៈដ៏ប៉ិនប្រសប់នៃសិល្បករកម្ពុជានៅក្នុងបរិវេណប្រាសាទនៅតំបន់អង្គរ ។ បន្ទាប់ពីទស្សនាប្រាសាទនៅអង្គរ ស្នាដៃសិល្បៈសិលាចារឹក និងរូបចម្លាក់ផ្សេងៗ សមាជិកគណៈប្រតិភូបក្សកុម្មុយនិស្តម៉ាក្ស-ឡេនីនបារាំងទាំងនោះ បានកត់សម្គាល់ថា ប្រជាជនកម្ពុជាគឺជាមនុស្សដែលបានសាងឡើងនូវភាពអង់អាចដ៏ពិសិដ្ឋ ដែលខុសទាំងស្រុងទៅនឹងអ្វីដែលជាពាក្យឃោសនាបង្កាច់បង្ខូចនៃពួកចក្រពត្តិនិយមពួកអាណានិគមនិយមចាស់និងថ្មី និងពួកចូលចិត្តវាតទីនៅអន្តរជាតិ »[(២៥)] ។

*តើពួកម៉ាក្សនិយមបារាំងទាំងនោះ ពិតជាឆោតល្ងង់ទៅធ្វើការអះអាងដែលគ្មានការពិតនោះដែរឬទេ? វាមានភាពស្រដៀងគ្នាទៅនឹងអ្នកដែលបានទៅទស្សនាប្រទេសអាល្បានីក្នុងកាលជំនាន់ណាស៊ី ដែលពួកគេត្រូវគេបង្ហាញឲ្យឃើញពីស្ថាបត្យកម្មវិហារគ្រិស្តសាសនាដ៏រុងរឿង ដើម្បីជាការអះអាងថានៅប្រទេសនេះ មិនមានបន្ទាយឃុំឃាំងអ្នកទោសនោះទេ ។*

*នៅដើមខែវិច្ឆិកា ឆ្នាំ ១៩៧៥ ចំណងការទូតត្រូវបានបង្កើតឡើងជាមួយនឹងប្រទេសថៃ ដោយលោក ឆាតឆាយ ឈុនហះវ៉ាន់ (ជាតិជាយ ជុណ្ហៈវ័ណ្ណ) ដែលក្រោយមក ក្លាយទៅជារដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រោយមកទៀត គឺក្នុងឆ្នាំ ១៩៧៨ បានក្លាយទៅជារដ្ឋមន្ត្រីក្រសួងការបរទេស ។ លោកបានធ្វើដំណើរជាលើកដំបូងមកក្រុងភ្នំពេញ ដោយបើកយន្តហោះម៉ាស៊ីនពីររបស់លោកដោយ*

---

**(២៣)** ផ្នែកព័ត៌មានផ្សព្វផ្សាយពីបរទេស ថ្ងៃទី ៤ តុលា ១៩៧៨, អាស់ ៥ ។ កំណត់បណ្ណាធិការ ÷ សម្រង់នេះ ត្រូវបានបកប្រែពីភាសាអង់គ្លេស ព្រោះរកអត្ថបទដើមជាខេមរភាសាពុំឃើញ ។

**(២៤)** ផ្នែកព័ត៌មានផ្សព្វផ្សាយពីបរទេស ថ្ងៃទី ៤ តុលា ១៩៧៨, អាស់ ៥ ។

**(២៥)** ផ្នែកព័ត៌មានផ្សព្វផ្សាយពីបរទេស ថ្ងៃទី ១៩ កញ្ញា ១៩៧៨, អាស់ ៥ ។ កំណត់បណ្ណាធិការ ÷ សម្រង់នេះ ត្រូវបានបកប្រែពីភាសាអង់គ្លេស ព្រោះរកអត្ថបទដើមជាខេមរភាសាពុំឃើញ ។

*ខ្លួនឯងផ្ទាល់ ។ ចំណងការទូតដ៏ល្អជាមួយប្រទេសជិតខាងនេះ បានរក្សាពេញមួយសម័យបដិវត្ត ហើយវាមានកម្រិតខ្ពស់បំផុតនៅពេលដែលមានការបង្កើតជើងយន្តហោះពាណិជ្ជកម្ម ដែលហោះហើរមួយសប្តាហ៍មួយជើង រវាងបាងកកនិងសៀមរាប ចាប់តាំងពីថ្ងៃ ១៧ វិច្ឆិកា ឆ្នាំ ១៩៧៨ ទៅ*(២៦) ។

## ឃ. ចុងបញ្ចប់នៃល្បែងនៅសៀមរាប

*នៅចុងឆ្នាំ ១៩៧៨ តើនៅមានកស្តុតាងណាខ្លះ ដើម្បីលាតត្រដាងពីរបបផ្តាច់ការទាំងស្រុងដែលបង្កើតឡើងដោយអង្គការនេះ ? មានសញ្ញាចង្អុលបង្ហាញថា សង្គមកុម្មុយនិស្តដ៏ព្រៃផ្សៃនេះកំពុងតែឈានទៅរកភាពផុយស្រួយ ។ នៅប៉ុន្មានខែចុងក្រោយនៃឆ្នាំ ១៩៧៨ វាបានបង្ហាញកាន់តែច្បាស់ថា ការគំរាមកំហែងរបស់វៀតណាមចង់ឈ្លានពាននោះ គឺជាការពិត ។ ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យបានទទូចសុំជំនួយពីចិន ដោយស្នើមិនត្រឹមតែផ្តល់ជំនួយជាអាវុធប៉ុណ្ណោះទេ តែសុំឲ្យជួយបញ្ជូនទាហានផងដែរ ។ ចិនយល់ព្រមឲ្យជំនួយជាអាវុធ តែបដិសេធក្នុងការបញ្ជូនទាហាន នៅខណៈដែលនយោបាយក្រុងប៉េកាំងមានការផ្លាស់ប្តូរដោយទោរទន់ទៅរកលោក តេង ស៊ាវភីង ។ ពួកខ្មែរក្រហមបានចាប់ផ្តើមបើកចំហប្រទេស និងស្វះស្វែងរកមិត្តថ្មីៗ នៅក្រៅប្រទេស ក៏ដូចជាអ្នកគាំទ្រនៅក្នុងប្រទេសផងដែរ ។ ពួកគេបានផ្លាស់ប្តូរនយោបាយចំពោះក្រុមបញ្ញវន្តដែលត្រឡប់មកពីបរទេស ។ ពីមុន ពួកខ្មែរក្រហមបានចាប់ពួកគេឃុំក្នុងជំរំអប់រំ និងបានសម្លាប់ពួកគេអស់រាប់រយនាក់ ឥឡូវបែរជាមកព្យាយាមលួងលោមពួកនេះឲ្យចូលបម្រើបដិវត្តន៍វិញ ។ រីឯ អៀង សារី ក៏ប្រែជាមានភាពញញឹមរាក់ទាក់នៅឯជំរំបឹងត្របែក ដែលជាតំបន់មួយស្ថិតនៅខាងត្បូងក្រុងភ្នំពេញ ហើយក៏ជាកន្លែងដែលគេប្រមូលផ្តុំបញ្ញវន្តទាំងនោះ ។ ពួកគេក៏ធ្វើការផ្លាស់ប្តូរខេត្តសៀមរាបឲ្យក្លាយទៅជាភូមិភាគពិសេស ដើម្បីស្វាគមន៍ឲ្យបានកាន់តែរាក់ទាក់ដល់គណៈប្រតិភូបរទេស ក៏ដូចជាអ្នកទេសចរធម្មតាផងដែរ ។*

*នៅរយៈពេលចុងក្រោយនៃឆ្នាំ ១៩៧៨ មានការផ្លាស់ខុសពីមុនស្រឡះ នៅទីរួមខេត្តសៀមរាប ។ បុរសដែលទទួលខុសត្រូវសម្អាតទីក្រុង គឺឈ្មោះ អ៊ី ឈាន ដែលជាអតីតអ្នកការពាររបស់ ប៉ុល ពត និង អៀង សារី កាលពីពេលនៃការចាប់ផ្តើមប្រយុទ្ធក្នុងបដិវត្តន៍ដំបូងនៅខេត្តរតនគិរី ហើយដែលសព្វថ្ងៃនេះ គឺជាអភិបាលក្រុងប៉ៃលិន ដោយមានឈ្មោះ អៀង វុទ្ធី ជាអនុប្រធានរបស់គាត់ ។ ការផ្លាស់ប្តូរនៅក្រុងសៀមរាប នៅចុងឆ្នាំ ១៩៧៨ មានន័យធ្វើយ៉ាងណាឲ្យវាអាចទទួលយកបានក្នុងការជ្រើសរើស និងគ្រប់គ្រងឲ្យបានតឹងរ៉ឹងបំផុត ចំពោះភ្ញៀវទេសចរបរទេស ។ លោក ឡុង នរិន្ទ*(២៧) *ដែលជាជំនួយការដ៏ជឿជាក់របស់ អៀង សារី ហើយក៏ធ្លាប់បានបម្រើការជំយូរធ្វើជាសន្តិសុខរបស់*

---

**(២៦)** ព័ត៌មាននេះគឺស្ថិតនៅក្នុងកថាខ័ណ្ឌបីចុងក្រោយនៃអត្ថបទនេះ ដកស្រង់ចេញពីជំពូកទី ១៣ នៃសៀវភៅ *Itinéraire d'un intellectuel khmer rouge* [**សាចតាររបស់បញ្ញាជនខ្មែរក្រហមម្នាក់**] សរសេរដោយលោក ស៊ួង ស៊ីគឿន ដែលនឹងត្រូវចេញនាពេលឆាប់ៗ នេះ នៅប៉ារីស ដោយគ្រឹះស្ថានបោះពុម្ពផ្សាយ អេឌីស៊ីយ៉ុងឌុយសែរហ្វ៍ (Éditions du Cerf) ។

**(២៧)** កើតនៅឆ្នាំ ១៩៣៨, សម្ភាសនៅថ្ងៃទី ២៨ សីហា ១៩៩៨ និងថ្ងៃទី ២៤ មករា ២០០១ ។

សម្តេចព្រះ សីហនុ ក្នុងព្រះបរមរាជវាំង ត្រូវបានបញ្ជូនទៅសៀមរាប ដើម្បីរៀបចំទីក្រុងឲ្យបានល្អប្រសើរ ដើម្បីត្រៀមទទួលគណៈប្រតិភូជប៉ុន ដែលនឹងមកធ្វើទស្សនកិច្ចនៅចន្លោះខែតុលានិងវិច្ឆិកា ឆ្នាំ ១៩៧៨ ។ ព្រលានយន្តហោះក៏ចាប់បើកឲ្យដំណើរការឡើងវិញ ស្របពេលដែលតាម៉ុកបញ្ជូនកុមារចំនួន ៦០០ នាក់ឲ្យទៅបោសសម្អាតប្រាសាទ ។ ប៉ុន្តែ កត្តាដែលមានការផ្លាស់ប្តូរខ្លាំងនោះ គឺការបិទគុក និងការដោះលែងអ្នកទោស ។ តើវាជាសញ្ញានៃចុងបញ្ចប់របស់របបផ្តាច់ការនេះឬ ?

អ្នកស្រី អេលីហ្សាបិថ បេគ័រ (Elizabeth Becker) និងអ្នករួមដំណើរពីររូបទៀតរបស់គាត់ គឺលោក ម៉ាល់ខលម កាដវែល (Malcolm Caldwell) និង រីឆាដ ដឹតដម៉ែន (Richard Dudman) គឺជាអ្នកដែលស្ថិតនៅក្នុងចំណោមអ្នកត្រូវបានគេទាញយកផលប្រយោជន៍ តាមរយៈការមកទស្សនារបស់ពួកគេ និងពួកគេត្រូវបានគេនាំឲ្យដើរទស្សនាលើចម្ងាយផ្លូវជាង ១០០០ គ.ម. ទូទាំងប្រទេស ។ ជាអកុសល សម្រាប់អង្គការ អ្នកស្រី អេលីហ្សាបិថ បេគ័រ មិនមានជាប់ជិតជាមមនោគមវិជ្ជាអ្វីនោះទេ ហេតុដូច្នេះហើយ ទើបអ្នកស្រីអាចសរសេរសៀវភៅដ៏ល្អមួយក្បាល ដែលមានទស្សនទាននៅលើស្ថានភាពនៃមហន្តរាយរបស់កម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ ១៩៧៨ ។ ការបង្ហាញរបស់អ្នកស្រី ហាក់ដូចជាខ្វី តែវាអាចបង្ហាញឲ្យយើងបានដឹងគ្រប់គ្រាន់ ។ អ្នកស្រីហាក់មិនមានភាពរំភើបជ្រុលក្នុងការលាតត្រដាងពីតថភាពនៃអ្នកក្រីក្រអនាថាទាំងនោះឡើយ និងប្រាថ្នាចង់ឲ្យរបបបដិវត្តមួយនេះ ប្រើប្រាស់សមត្ថភាព និងការពេញចិត្តធ្វើវិភាគទាននៃអ្នកជំនាញការខាងការងារអតិរេក្ស និងក្រុមកម្មករដែលអ្នកទាំងនោះនៅរស់នៅឡើយមកទល់ពេលនោះ ។ អ្នកស្រីក៏បានដឹងពីលោក ដួន ប្រសិទ្ធ ដែលជាមគ្គុទ្ទេសក៍របស់អ្នកស្រីថា ជីវិតរបស់ពួកគេមិនត្រូវបានប៉ះពាល់ឡើយ ប៉ុន្តែ ជំនាញរបស់អ្នកទាំងនោះ មិនត្រូវបានប្រើប្រាស់ឲ្យបានសមស្របឡើយ ។ ចំណុចនេះ គាត់ (ដួន ប្រសិទ្ធ) បានលើកឡើងនូវចំណុចត្រឹមត្រូវ ។ ប្រាសាទទាំងឡាយ ក៏ដូចជាសារមន្ទីរជាតិដែរ ត្រូវបានគេបោះបង់ចោល និងទទួលរងភាពទ្រុឌទ្រោម ដូចដែលអ្នកស្រីបានគូសបញ្ជាក់ប្រាប់ដោយការសោកស្តាយ[(២៨)] ។

បន្ទាប់ពី មាស ធនញ្ជ័យ[(២៩)] ត្រូវបានគេដោះលែងចេញពីគុកអាណានិគម នាពេលដែលគុកនេះត្រូវបានបិទ គ្រាមួយពេល គាត់កំពុងជួសជុលវិទ្យុ ស្រាប់តែបានឮគេជេរប្រមាថ ប៉ុល ពត និងរៀបរាប់ពីបទឧក្រិដ្ឋរបស់ ប៉ុល ពត ថា ជា «បន ប៉ុល ពត» ។ នៅថ្ងៃបន្ទាប់មក ក៏មានមីទិញដ៏ធំមួយ ហើយគេបានប្រកាសពីការវាយលុករបស់សត្រូវយួន ។ គេត្រូវការអ្នកស្ម័គ្រចិត្តទាំងឡាយ ដើម្បីទៅប្រយុទ្ធតទល់ តែមានមនុស្សតិចប៉ុណ្ណោះដែលបានចូលរួម រីឯអ្នកឯទៀតបាននាំគ្នារត់ព្យាយាមគេចវេះ ។ ពួកខ្មែរក្រហមបានប្រមូលផ្តុំគ្នានៅកន្លែងមួយ ដើម្បីបែងចែកអាវុធ ហើយពួកគេប្រែជាមានសភាពដូចជាភ័យខ្លាចចំពោះប្រជាជន ។ នៅថ្ងៃបន្ទាប់ កម្មាភិបាលខ្មែរក្រហមទាំងអស់បានរត់គេចដោយរទេះគោនៅវេលាម៉ោងប្រមាណ ២ រសៀល ហើយពេលនោះ គឺថ្ងៃ ១៧ ខែមករា ឆ្នាំ ១៩៧៩ ។

---

**(២៨)** សូមមើល *When the War Was Over, the Voices of Cambodia's Revolution and its People* [**នៅពេលដែលសង្គ្រាមបានរលត់ទៅ សំឡេងនៃបដិវត្តន៍កម្ពុជា និងប្រជាជនរបស់បដិវត្តន៍នោះ**] ញូយ៉ក, សៃម៉ុននិងស្ហូស្ទ័រ (Simon & Schuster) គ.ស. ១៩៨៦, ទ. ៤២៣ ។

**(២៩)** កើតក្នុងឆ្នាំ ១៩៤៨, សម្ភាសន៍នៅ ថ្ងៃទី ១០ សីហា ១៩៩៤ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាអ្នកជួសជុលវិទ្យុមួយនាក់ ។ ក្នុងឆ្នាំ ១៩៩៤ ជាតំណាងក្នុងតំបន់ឲ្យសមាគមការពារសិទ្ធិមនុស្សនៅកម្ពុជា ហៅកាត់ថា អាដហុក ។

## ង. អត្ថន័យនៃ អង្គរវត្ត សម្រាប់កម្ពុជាប្រជាធិបតេយ្យ

អង្គរវត្តជានិមិត្តរូបនៃអរិយធម៌មួយ ដែលពួកម៉ាក្សនិយមស្អប់ខ្ពើម ប៉ុន្តែផ្ទុយទៅវិញ ពួកខ្មែរក្រហមត្រូវបានភ្ជាប់ខ្លួនទៅនឹងប្រាសាទនេះ ។ វាបានបង្ហាញយ៉ាងច្បាស់នូវមហិច្ឆតារបស់ពួកគេ ដែលធ្លុតនឹងអំណាចនេះ ។ ថ្នាក់ដឹកនាំនៅជុំវិញ សាឡុត ស បានយកកំពូលនៃប្រាសាទទៅដាក់នៅលើទង់ជាតិបដិវត្តរបស់ខ្លួន ជំនួសឲ្យរូបញញួរនិងកណ្ដៀវ ។ វាមិនមែនតំណាងឲ្យវណ្ណៈអធន កម្មករ កសិករនោះទេ ប៉ុន្តែជាញើសឈាមរបស់មនុស្សច្រើនដូចហ្វូងស្រមោចនាំគ្នាទៅកាត់ដុំថ្មធំៗ ដឹកដញ្ជូនយកពីភ្នំគូលែនមក និងលើកដាក់ផ្គុំគ្នាដើម្បីបង្ហាញពីកិត្យានុភាពរបស់ព្រះរាជានិងព្រះអម្ចាស់ជីវិតលើត្បូងរបស់ពួកគេទៅវិញ ។ ស្របជាមួយនឹងនេះ វាក៏ជានិមិត្តរូបនៃទំហំការងារដ៏មហិមាដែរចំពោះគម្រោងរក្សាទឹកនាពេលរដូវប្រាំង ដែលវាជាជោគជ័យយ៉ាងធំធេងរបស់ប្រជាជនកម្ពុជាក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ តើអ្វីទៅជាតម្លៃរបស់មនុស្ស ?

អ្នកស្រី អេលីហ្សាបិថ បេគ័រ មានការភ្ញាក់ផ្អើល ដោយសម្គាល់ឃើញថា នៅសម័យបដិវត្តន៍ក្នុងប្រទេសកម្ពុជា រូបប្រាសាទអង្គរវត្តត្រូវបានគេព្យួរនៅតាមអគារ និងក្នុងបន្ទប់ទទួលភ្ញៀវដែលពួកយើងបានទៅដល់ ពោលគឺមិនមែនជារូបថតរបស់ ប៉ុល ពត ឬក៏ថ្នាក់ដឹកនាំដទៃទៀតនោះទេ ហើយក៏មិនមែនជារូបរបស់ កាល់ ម៉ាក្ស, ឡេនីន ឬ ចូហ្សេហ្វ ស្តាលីន ដូចនៅក្នុងប្រទេសវៀតណាមដែរ ។ មានតែអង្គរវត្តទេ ដែលមានលក្ខណៈគ្រប់គ្រាន់អាចក្លាយទៅជានិមិត្តរូបនៃបដិវត្តន៍កម្ពុជា[៣០] ។ រូបខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង នៅពេលដែលបានឃើញរូបថតប្រកបដោយការវាយឫក នៅក្នុងផ្ទះរបស់តាម៉ុក លើជម្រាលភ្នំដងរែកក្នុងស្រុកអន្លង់វែង នៅពេលដែលខ្ញុំបានទៅទស្សនាក្នុងឆ្នាំ ២០០១ ។ លោក ដួន មុំ ជាអ្នកទ្រឹស្តីនិយមដ៏សំខាន់មួយរូបរបស់ក្រុមអ្នកប៉ុលពតនិយម (ប្រសិនបើលទ្ធិរបស់ ប៉ុល ពត ពិតជាមាន) ហើយធ្លាប់ជាមិត្តរួមសាលារបស់លោក ប៊ែរណារដ៍-ហ្វ៊ីលីព្ព គ្រោស្លីយ៉េរ៍ នៅឯសាលាបឋមសិក្សាព្រះនរោត្តមក្នុងទីក្រុងភ្នំពេញ ។ នៅពេលដែលខ្ញុំបានទៅលេងលោក (លោក គ្រោស្លីយ៉េរ៍) នៅទីក្រុងរូអង់ លោកបានផ្តល់ឲ្យខ្ញុំនូវអត្ថបទមួយស្តីពីមិត្តភក្តិរួមសាលារបស់លោក ។ វាជាអត្ថបទមានចំណងជើងថា *La cité hydraulique angkorienne: exploitation ou surexploitation du sol ?*[៣១] **(បុរីធារាសាស្ត្រអង្គរ ៖ ការយកផលអំពីដី ឬការយកផលច្រើនហួសអំពីដី ?)** ។ អត្ថបទដែលហាក់ដូចជាបានដើរតួក្នុងការបើកនូវយុគសម័យថ្មីនៃការសិក្សាស្រាវជ្រាវ បានផ្តល់វិភាគទានដល់ការផ្លាស់ប្តូរចំណាប់អារម្មណ៍របស់អ្នកប្រវត្តិសាស្ត្រចំពោះប្រាសាទ ស្តេច និងព្រះញាតិវង្ស ដោយងាកទៅផ្តោតលើវិថីជីវិតដែលបានរៀបចំសម្រាប់មនុស្សធម្មតាវិញ ។ លោក គ្រោស្លីយ៉េរ៍ បានបន្ថែមថា យើងអាចយល់ប្រព័ន្ធទាំងនោះបានស៊ីជម្រៅ « តែតាមរយៈការស្វែងយល់ពីសហគមន៍ប៉ុណ្ណោះ » ហើយប្រព័ន្ធទាំងនោះក៏ « បដិសេធមិនឲ្យបុគ្គលតែម្នាក់ ឬគ្រួសារតែមួយក្រុមប៉ុណ្ណោះរឹបយកដីទាំងអស់ធ្វើជារបស់ខ្លួន » ។ តែម្យ៉ាងទៀត លោកក៏បានអះអាងដែរថា « ការឆ្កួតយសឆ្កួតបុណ្យអំណាចរបស់ស្តេចខ្មែរ បានជំរុញឲ្យពួក

---

**(៣០)** សូមមើល [នៅពេលដែលសង្គ្រាមបានរលត់ទៅ...] ទ. ៤២៣ ។

**(៣១)** *BEFEO* [ព្រឹត្តិបត្រសាលាបារាំងចុងបូព៌ា] លេខ ៦៦ គ.ស. ១៩៧៩, ទ. ១៦១–២០២ ។

ព្រះអង្គធ្វើការកសាងប្រាសាទកាន់តែធំ និងកាន់តែស្រស់ស្អាតឡើង ៗ ។ ការកសាងទាំងនោះ អាចសម្រេចទៅបាន លុះត្រាតែអំណាចកណ្តាលមានលក្ខណៈរឹងមាំបំផុត » ។ *ពាក្យរបស់លោក ហ្វ្រោស៍លីយ៉េរ៍ ទាំងនេះ ទំនងជាពាក្យដែលត្រូវចិត្តត្រូវថ្លើមនៃមនុស្សក្នុងមជ្ឈិមបក្សរបស់អង្គការ ។ ជាការប្លែកមែនទែន ដែលការសិក្សាស្រាវជ្រាវរបស់លោក ដែលជាមនុស្សមួយរូបបានការពារប្រាសាទទាំងអស់អាចប្រឆាំងនឹងពួកវៀតមិញនិងពួកខ្មែរក្រហម បែរជាត្រូវគេយកមកបម្រើឲ្យគោលនយោបាយដ៏ឧក្រិដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យនោះទៅវិញ ។*

*ការមើលឯកសារដែលសរសេរឡើងដោយលោក ដេវិឌ ឆាណ្ឌលែរ៍ ក្នុងសៀវភៅ* **ការប្រឈមមុខអតីតភាពកម្ពុជា**[៣២] *ក៏ធ្វើឲ្យមានការស្រងាកចិត្តផងដែរ ។ នៅក្នុងចំណុចចុងក្រោយនៃសំណេររបស់គាត់ក្រោយចំណងជើងថា «សោកនាដកម្មនៅប្រវត្តិសាស្ត្រកម្ពុជា» ឆ្នាំ ១៩៧៩ ហើយដែលឯកសារដដែលនេះដែលត្រូវបានត្រួតពិនិត្យឡើងវិញក្នុងឆ្នាំ ១៩៩៤ បានសម្គាល់ថា ៖*

> « នៅក្នុងចំណុចសំខាន់នៃការដឹកនាំក្នុងប្រពៃណីប្រទេសកម្ពុជា គឺហាក់ដូចជាមានការកេងយកចំណេញ ច្រើនជាងការបម្រើប្រយោជន៍រួម ហើយវាក៏មានសភាពដូចជា ការគ្រប់គ្រងជាជាងការសហប្រតិបត្តិការជាមួយគ្នា ។ ពាក្យថា “គ្រប់គ្រង” ... គឺវាស្មើនឹងពាក្យថា សោយ ឬ ឆី (ស៊ី) » [គ.ស. ១៩៧៩] ។ នៅពេលត្រឡប់ទៅខេត្តសៀមរាប ក្នុងឆ្នាំ ១៩៩២ រូបខ្ញុំមិនត្រឹមតែមានការភ្ញាក់ផ្អើលទៅនឹងភាពស្រស់ស្អាតនៃប្រាសាទប៉ុណ្ណោះទេ តែក៏មានការភ្ញាក់ផ្អើលទៅនឹងចំនួនដ៏ច្រើននៃប្រាសាទ ជាពិសេសគឺអង្គរវត្ត ដែលអាចយល់បានថា ការបង្ហាញនូវអំណាចនិងការគ្រប់គ្រងដ៏ខ្លាំងក្លា ។ ប្រាសាទអង្គរវត្ត នៅក្នុងន័យនេះ គឺជាការអះអាងមួយដែលធ្វើឡើងនៅអំឡុងគ្រិស្តសតវត្សរ៍ទី ១២ សម្រាប់តែមនុស្សតែមួយរូបប៉ុណ្ណោះ គឺស្តេច សូរ្យវរ្ម័ន ទី ២ ដែលបានយកប្រាសាទទុកជាផ្នូរសម្រាប់ព្រះអង្គ ។ វាមិនត្រឹមតែជាវិមានដ៏ធំបំផុតក្នុងពិភពលោក តែវាក៏ជាផ្នូរសម្រាប់បុគ្គលដ៏ធំជាងគេ លើពិភពលោកផងដែរ » [គ.ស. ១៩៩៤] ។

*ពួកអ្នកធ្វើបដិវត្តន៍បានផ្អែកយ៉ាងរឹងមាំទៅលើប្រាសាទអង្គរវត្តនៅក្នុងពាក្យស្លោក សុន្ទរកថា និងនៅលើទង់ជាតិដ៏ជាតិនិយមរបស់ពួកគេ ។ ដើម្បីធ្វើឲ្យមានភាពល្បីខ្ទរខ្ទារ ខ្លឹមសារដ៏មានឥទ្ធិពលនៃដំហានមហាលោតផ្លោះរបស់ពួកគេ តែងលើកឡើងម្តងហើយម្តងទៀតនៅរាល់ឱកាសជាផ្លូវការថា* «ប្រសិនបើប្រជាជនរបស់យើង អាចកសាងអង្គរវត្តបានហើយ នោះពួកគេក៏អាចធ្វើអ្វី ៗ ផ្សេងទៀតបានដែរ[៣៣]» *។ ប៉ុល ពត បានប្រកាសនៅក្នុងសុន្ទរកថាដែលមានរយៈពេល ៥ ម៉ោង កាលពីថ្ងៃទី ២៧ ខែតុលា ឆ្នាំ ១៩៧៧ ដែលជាពេលដែលខ្លួនបានសារភាពថា* **អង្គការ** *គឺជាបក្ស*

---

**(៣២)** *Facing the Cambodian Past, Selected Essays* [**ការប្រឈមមុខអតីតភាពកម្ពុជា អត្ថបទសារតល្បងជ្រើសរើស**] ឈៀងម៉ៃ, ស៊ិលក៍វ៉ឺមប៊ូក្ស គ.ស. ១៩៩៦–១៩៩៨ ។

**(៣៣)** ផ្នែកព័ត៌មានផ្សព្វផ្សាយពីបរទេស ថ្ងៃទី ៤ តុលា ១៩៧៧, អាស់ ២៦ ។ កំណត់បណ្ណាធិការ ៖ សម្រង់នេះ ត្រូវបានបកប្រែពីភាសាអង់គ្លេស ព្រោះរកអត្ថបទដើមជាខេមរភាសាពុំឃើញ ។

*កុម្មុយនិស្តកម្ពុជា ។ ឧទាហរណ៍ មានពាក្យស្លោកមួយបានលើកឡើងថា ៖* «**តាមរយៈការអភិវឌ្ឍយ៉ាងរហ័ស ប្រទេសរបស់យើងនឹងល្អលើសសម័យអង្គរទៅទៀត**» *ហើយសុន្ទរកថារបស់ កែ ពក នៅមុខប្រាសាទអង្គរវត្ត ក៏បានលើកឡើងដូចគ្នានេះផងដែរ ។ វាបានលាតត្រដាងយ៉ាងច្បាស់ពីគោលបំណងគ្មានព្រំដែនរបស់ពួកអ្នកបដិវត្ត ហើយដែលមិនបានបារម្ភអ្វីសោះទៅលើតថភាពជាក់ស្តែងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងតម្លៃ និងការឈឺចាប់នៃជីវិតមនុស្ស*(៣៤) *។*

*ដោយមិនភ័យខ្លាចទៅពីការប្រឆាំងតប់តនឹងពួកគេ គណៈបក្សកុម្មុយនិស្តកម្ពុជា បានបង្ហាញថា ប្រាសាទអង្គរវត្ត គឺជាគំរូគួរតែត្រាប់តាម ហើយគំរូផ្សេងទៀតដែលផ្ទុយពីនេះ គួរច្រានចោល ។ ពួកគេបានកោតសរសើរពីសមត្ថភាពនៃបុព្វបុរសរបស់ខ្លួន ដើម្បីជំរុញកសាងឡើងនូវស្នាដៃដែលមានលក្ខណៈដូចគ្នាទៅនឹងស្នាដៃរបស់ព្រះចៅផារ៉ាអុងនៅអេហ្ស៊ីប និងក៏ដើម្បីគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក្នុងគោលបំណងធ្វើការផ្ទុះបញ្ជាំងពីពាក្យស្លោក* **មហាលោតផ្លោះ** *របស់ពួកគេផងដែរ ។ ពីមុនមក ពួកគេបានបំភ្លេចចោលអង្គរវត្តដែលជា* **គំរូមួយតាំងពីប្រមាណជាជាងពីរពាន់ឆ្នាំមកហើយ ហើយប្រជាជនរបស់យើងរស់នៅក្នុងសភាពទីទាល់ក្រ និងភាពអស់សង្ឃឹមយ៉ាងខ្លាំងក្លា**(៣៥) *។*

*ចាប់តាំងពីពេលនោះមក ប្រាសាទអង្គរវត្តដ៏ធំនេះ គឺត្រឹមតែជាកន្លែងចេតិយស្ថានមួយ ដែលត្រូវបានគេអនុញ្ញាតឲ្យមនុស្សសាមញ្ញចូលបានតែក្នុងកំពែងទីមួយប៉ុណ្ណោះ ដោយមានលក្ខណៈដូចគ្នាទៅនឹងទីក្រុងទាំងអស់ដែលពួកខ្មែរក្រហមបានគ្រប់គ្រងដូច្នោះដែរ ។ នៅសម័យអង្គរ មិនមានឡើយនូវរូបិយប័ណ្ណ ។ របស់របរគ្រប់យ៉ាងធ្វើឡើងដោយការដោះដូរស្ងួបរ្បីតែមនុស្ស ដែលត្រូវគេមាក់ងាយថាជាទាសករឬអ្នកបម្រើ ។ ប៉ុល ពល និងខួរក្បាលរបស់អង្គការ មានលក្ខណៈដូចជាជាទេវរាជ*(៣៦) *។ ក៏ដូចទៅនឹងអធិរាជនៃប្រទេសចិន ដែលទីក្រុងត្រូវស្ថិតនៅក្រោមការហាមឃាត់ពីស្តេច ឬក៏នៅពេលក្រោយមកទៀត ដូចលោក ម៉ៅ សេទុង ដែលរស់នៅក្នុងទីក្រុងដែលស្ថិតនៅដាច់ឆ្ងាយពីគេ ហាមឃាត់មនុស្សគ្រប់រូបមិនឲ្យចូលទៅ លើកលែងតែអ្នកការពារ និងអ្នកបម្រើរបស់លោកចេញ ។*

## សេចក្តីសន្និដ្ឋាន

*ប្រាសាទអង្គរវត្ត ពិតជាបានក្លាយទៅជានិមិត្តរូបនៃភាពរុងរឿង កាលពីអតីតកាលរបស់ប្រទេសកម្ពុជា ចាប់តាំងពីសម័យអាណានិគមបារាំងមក ។ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អង្គរវត្តបានក្លាយទៅជានិមិត្តរូបនៃការយល់ខុសដ៏ធំរបស់អង្គការ ។ បើ «សត្រូវរបស់មនុស្ស» ត្រូវបានសម្លាប់កាន់តែច្រើន ដើម្បីជាការគោរពចំពោះអង្គការ នោះបទពិសោធន៍របស់ប្រជាជនកម្ពុជាក្នុងដួរបដិវត្ត*

---

**(៣៤)** សូមមើល៖ ហង់រី ឡូការដ៍ *Pol Pot's Little red book, or the Saying of Angkar* [**សៀវភៅក្រហមតូចរបស់ ប៉ុល ពត ឬភាសិតរបស់អង្គការ**] ឈៀងម៉ៃ, ស៊ិលក៍វ៉ឹមប៊ូក្ស ខែឧសភា គ.ស. ២០០៤ ទ. ៧៥ ។

**(៣៥)** ផ្នែកព័ត៌មានផ្សព្វផ្សាយពីបរទេស ថ្ងៃទី ៤ តុលា ១៩៧៧, អាស់ ២៥ ។ កំណត់បណ្ណាធិការ៖ សម្រង់នេះ ត្រូវបានបកប្រែពីភាសាអង់គ្លេស ព្រោះរកអត្ថបទដើមជាខេមរភាសាពុំឃើញ ។

**(៣៦)** ប្រ៊ុយណូ ដាហ្សាំង្ស (Bruno Dagens), *Les Khmers* [**ជនជាតិខ្មែរ**] ប៉ារីស, ឡេប៉ែលឡែត្រ គ.ស ២០០៣ ទ. ៨៨ ។

*កាន់តែបរិសុទ្ធ ។ ការធ្វើឲ្យប្រទេសដ៏តូចនេះដើរត្រឡប់ទៅក្រោយកាន់តែខ្លាំង វាមិនត្រឹមតែក្លាយធ្វើជាគំរូមួយនៃតំបន់អាស៊ីអាគ្នេយ៍នេះប៉ុណ្ណោះទេ តែវាក៏ជាពន្លឺមួយនៃពិភពលោកដែលកំពុងអន់ថយផងដែរ ។ ទស្សនវិស័យចំពោះពិភពលោកដ៏ឆ្កួតលេលានេះ គឺជាការរួមផ្សំគ្នានៃគំនិតដ៏អន់ថយរបស់បុគ្គលសំខាន់ៗ មាន ប៉ុល ពត, នួន ជា និង សុន សេន ដែលជាមេក្លោងនៃរាល់ការកាប់សម្លាប់ដែលមិនមានទីបញ្ចប់ និងក៏ជាអ្នកដែលពន្លឿនឲ្យមានការកាប់សម្លាប់ផងដែរ ។ នៅក្នុងបរិបទនៃអត្ថបទនេះ គំរូនៃការគិតបែបនេះ បានបង្ហាញយ៉ាងច្បាស់ តាមរយៈការបរិយាយដ៏បូរបាច់របស់ កែ ពក ដែលបានចង្អុលទៅកាន់កំពូលប្រាសាទអង្គរវត្ត នៅចំពោះមុខបក្សពួក ៥០០០ នាក់រួមទាំងព្រះសង្ឃជាច្រើនអង្គផងដែរនោះ បានអះអាងថា នេះគឺជាថ្ងៃដ៏ពិសេសបំផុតនៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាក្នុងរយៈពេល ២០០០ ឆ្នាំមកនេះ ។ ពួកខ្មែរក្រហមបានខ្នះខ្នែងដើម្បីឲ្យបានចូលដល់ទីរួមខេត្តសៀមរាប ក្នុងថ្ងៃដូចគ្នានៃការចូលកាន់កាប់ក្រុងភ្នំពេញ និងបីថ្ងៃក្រោយមកទៀត ទើបចូលទៅដល់ទីរួមខេត្តកំពង់ធំ ។ ទន្ទឹមនឹងនេះ នៅទីបរិវេណប្រាសាទអង្គរវត្ត ពួកគេបានប្រញាប់ប្រញាល់រៀបចំសម្រាប់ពិធីបុណ្យនៃការទទួលជោគជ័យដ៏អស្ចារ្យ ។ ពួកគេបានរៀបចំពិធីបុណ្យដែលមានរយៈពេលបីថ្ងៃដូចគ្នាទៅនឹងការប្រារព្ធពិធីបុណ្យខ្មែរជាប្រពៃណីមកដែរ ។ នៅក្នុងតថភាពជាក់ស្តែង កម្ពុជាប្រជាធិបតេយ្យ ដែលគេបានឃើញនៅខេត្តសៀមរាប គឺជាតំណាងឲ្យដំហាននៃការលោតផ្លោះត្រឡប់ទៅក្រោយយ៉ាងវែង ។ ប្រាសាទអង្គរ រំលេចឡើងនូវភាពរុងរឿងនៃការងារដ៏មហិមា ដោយប្រើតែកម្លាំងមនុស្សប៉ុណ្ណោះ ហើយដែលមិនមានរាប់បញ្ចូលនូវគ្រឿងម៉ាស៊ីនទំនើបទេ ។* **« ប្រសិនបើបុព្វបុរសរបស់យើងអាចសម្រេចស្នាដៃដូចនេះ យើងក៏អាចធ្វើបានដូច្នោះដែរ »** *។ ទាំងនេះ ហាក់ដើរតួជាមូលដ្ឋាននៃមនោគមវិជ្ជា ។*

*របបនេះតែងតែមានភាពញ័ររញ្ជួយ ។ ដោយឡែក វាទំនងជានឹងមិនបានបង្កើតឡើង នូវសម័យកាលដែលពោរពេញដោយអំពើហិង្សា និងការភ័យខ្លាចយ៉ាងនេះទេ ប៉ុន្តែ ដើម្បីធ្វើឲ្យអ្នកប្រឆាំងស្ងប់ស្ងាត់ ត្រូវតែពួកគេសម្លាប់ បើទោះបីជាមានទំហំកាន់តែច្រើនឡើងៗក៏ដោយ ។ ទំហំនៃការប្រមាញ់ជីវិតមនុស្សដែលជាសត្រូវ គឺមានទំហំធំធេងដូចប្រាសាទអង្គរវត្តដូច្នោះដែរ ។ យ៉ាងណាក៏ដោយ ទីជុំវិញនៃការប្រៀបធៀបខាងលើនេះ ដូចលោក អាឡាំង ហ្វូវែស្ត បានចង្អុលបញ្ជាក់ថា* **« បាតុភូតដ៏ហួសប្រមាណទាំងពីរនោះ បំប្លែងការយល់ឃើញ »**(៣៧) *របស់យើងចំពោះប្រវត្តិសាស្ត្រប្រទេសកម្ពុជា ៕*

**(៣៧)** សូមមើល *Cambodge contemporain* [ប្រទេសកម្ពុជាបច្ចុប្បន្ន] បាងកក, អ៊ីរ៉ាសិក (IRASEC) និង ឡេហ្សាំងដ្យ៍សាវ៉ង់ត្ស៍ (Les Indes savantes) គ.ស ២០០៨ ទ. ១៧ ៕